សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបបទឃាតកម្ម

# និង

# បទឃាតកម្មគិតទុកជាមុន

ស្រាវជ្រាវ ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. នី សៀវហ៊ុន**

សាស្ត្រាចារ្យណែនាំ

លោក **កេត សុជាតិ**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ០១

**ជំពូកទី ១ ៖ បទឃាតកម្ម**

**១.១.និយមន័យនៃបទឃាតកម្ម** ........................................ ០៦

**១.២.ធាតុផ្សំនៃបទឃាតកម្ម** ........................................ ០៧

**១.២.១. ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម** ........................................ ០៧

១.២.១.១. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ........................................ ០៨

១.២.១.២. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល ........................................ ០៨

**១.២.២. ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម** ........................................ ០៩

១.២.២.១. អំពើសម្លាប់មនុស្ស ឬផ្តាច់ជីវិតមនុស្ស ឬប្រល័យជីវិតមនុស្ស ........................................ ០៩

១.២.២.២. លក្ខណៈសម្បត្តិនៃជនរងគ្រោះ ........................................ ០៩

ក. ត្រូវតែកើតចេញពីផ្ទៃម្តាយមកហើយនៅមានជីវិត ........................................ ០៩

ខ. ត្រូវតែជាអ្នកដទៃ ក្រៅពីជនល្មើសជាដាច់ខាត ........................................ ១០

គ. ត្រូវតែជាមនុស្សដែលរស់រានមានជីវិត ........................................ ១០

**១.២.៣. ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម** ........................................ ១២

១.២.៣.១. ករណីមានចេតនាចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ ........................................ ១២

១.២.៣.២. ករណីមានការយល់ព្រមពីជនរងគ្រោះ ........................................ ១៣

១.២.៣.៣. ករណីនៃការការពារស្របច្បាប់និងករណីមានការភ័ន្តច្រឡំ ........................................ ១៣

**១.៣. ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម** ........................................ ១៤

**១.៣.១. ករណីគ្មានស្ថានទម្ងន់ទោស** ........................................ ១៤

**១.៣.២. ករណីមានស្ថានទម្ងន់ទោស** ........................................ ១៤

១.៣.២.១. ឃាតកម្មគិតទុកជាមុន ........................................ ១៤

១.៣.២.២. ឃាតកម្មដោយការប្រើថ្នាំពុល ........................................ ១៤

១.៣.២.៣. ឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ........................................ ១៥

ក. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុ ........................................ ១៥

ខ. បុគ្គលដែលជានារីមានគភ៌ ........................................ ១៦

គ. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព ................ ១៦
ឃ. បុគ្គលដែលជាអ្នករាជការសាធារណៈ ................ ១៧
១.៣.២.៤. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ ................ ១៩
ក. ករណីជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី មិនទាន់ប្ដឹង ................ ១៩
ខ. ករណីសាក្សី មិនទាន់ផ្ដល់សក្ខីកម្ម ................ ២០
គ. ករណីជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងរួចហើយ ................ ២០
ឃ. ករណីសាក្សី បានផ្ដល់សក្ខីកម្មរួចហើយ ................ ២០
១.៣.២.៥. បទឃាតកម្មដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ................ ២១
ក. ប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ................ ២១
ខ. ប្រព្រឹត្តនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ................ ២១
១.៣.២.៦. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ................ ២២
ក. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ................ ២២
ខ. ឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ ................ ២២
**១.៤. ទោសបន្ថែមនៃបទឃាតកម្ម ៖ ប្រភេទ និងរយៈពេល** ................ ២៣
**ជំពូកទី ២ បទឃាតកម្មគិតទុកជាមុន**
**២.១. និយមន័យនៃបទល្មើសឃាតកម្មគិតទុកជាមុន** ................ ២៥
**២.១.១. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលឆ្នាំ ១៩៩២** ................ ២៥
**២.១.២. ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩** ................ ២៥
**២.២. ធាតុផ្សំនៃបទល្មើស** ................ ២៥
**២.២.១. ធាតុផ្សំនីត្យានុកូល** ................ ២៦
២.២.១.២. ចាស់ ................ ២៦
២.២.១.២. ច្បាប់ថ្មី ................ ២៦
**២.២.២. ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈនៃបទល្មើស** ................ ២៦
២.២.២.១. ច្បាប់ចាស់ ................ ២៦
ក.ការគិតទុកជាមុន ................ ២៧
ខ.ការពួនស្ទាក់ ................ ២៧

គ.អំពើចោរកម្ម ឬអំពើរំលោភសេពសន្ថវៈ ..... ២៧
២.២.២.២. ច្បាប់ថ្មី ..... ២៨
ក.ការគិតទុកជាមុន ..... ២៨
ខ.ការពួនស្ទាក់ ..... ២៩
គ.បទប្បញ្ញត្តិដែលចែងពីរូបភាពនៃឃាតកម្មគិតទុកជាមុន ..... ២៩
គ.១.ច្បាប់ស្តីការគ្រប់គ្រងអាស៊ីដខ្លាំង ..... ៣០
គ.២.បទរាជឃាតកម្ម ..... ៣០
**២.២.៣. ធាតុផ្សំអត្តនោម័ត** ..... ៣០
២.២.៣.១. ច្បាប់ចាស់ ..... ៣០
២.២.៣.២. ច្បាប់ថ្មី ..... ៣១
**២.៣. ទោសដែលត្រូវអនុវត្ត** ..... ៣១
**២.៣.១. មូលទោស** ..... ៣១
២.៣.១.១.ទោសដាក់ពន្ធនាគារ ..... ៣១
២.៣.១.២.ទោសពិន័យ ..... ៣១
**២.៣.២. ទោសបន្ថែម** ..... ៣១
**ជំពូកទី ៣ ការប្រៀបធៀបបទល្មើសទាំងពីរ**
**៣.១. ចំណុចដូចគ្នា** ..... ៣៣
**៣.១.១.ការចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩** ..... ៣៣
៣.១.១.១.ការចែងនៅក្នុងគន្ថី ..... ៣៤
៣.១.១.២.ការចែងនៅក្នុងមាតិកា ..... ៣៤
៣.១.១.៣.ការចែងនៅក្នុងជំពូក ..... ៣៤
៣.១.១.៤.ការចែងនៅក្នុងផ្នែក ..... ៣៥
**៣.១.២.ប្រភេទនៃបទល្មើស** ..... ៣៥
**៣.១.៣.បុគ្គលដែលពាក់ព័ន្ធទៅនឹងបទល្មើស** ..... ៣៦
៣.១.៣.១.ជនល្មើស ..... ៣៦
៣.១.៣.២.ជនរងគ្រោះ ..... ៣៧
**៣.១.៤.អំពើ និងបច្ច័យ** ..... ៣៨

**៣.១.៥.អាជ្ញាយុកាល** ........................................ ៣៨
៣.១.៥.១.អាជ្ញាយុកាលនៃបទល្មើស ........................................ ៣៨
៣.១.៥.១.អាជ្ញាយុកាលនៃទោស ........................................ ៣៩
**៣.១.៦.ទោសបន្ថែម និងការប៉ុនប៉ង** ........................................ ៤០
**៣.២. ចំណុចខុសគ្នា** ........................................ ៤០
**៣.២.១. និយមន័យនៃបទល្មើសទាំងពីរ** ........................................ ៤០
**៣.២.២. ធាតុផ្សំនៃបទល្មើសទាំងពីរ** ........................................ ៤១
៣.២.២.១. ធាតុផ្សំនីត្យានុកូល ........................................ ៤១
៣.២.២.២. ធាតុផ្សំសត្យានុម័ត ........................................ ៤១
ក.អំពើនៃការគិតទុកជាមុន ឬ ពួនស្ទាក់ ........................................ ៤១
ខ.លទ្ធផលនៃការប្រព្រឹត្តអំពើ ........................................ ៤២
គ.ពេលវេលានៃការប្រព្រឹត្តអំពើ ........................................ ៤២
ឃ.មូលហេតុនៃការប្រព្រឹត្តអំពើ ........................................ ៤៣
ង.លទ្ធភាពក្នុងការកែខ្លួនរបស់ជនល្មើស ........................................ ៤៤
ច.គោលដៅរបស់ជនល្មើសចំពោះជនរងគ្រោះ ........................................ ៤៥
៣.២.២.៣. ធាតុផ្សំអត្តនោម័ត ........................................ ៤៦
៣.២.២.៤. ទោសដែលត្រូវអនុវត្ត ........................................ ៤៦
ក.មូលទោស ........................................ ៤៦
ខ. ស្ពានទម្ងន់ទោស ........................................ ៤៦
**សេចក្តីសន្និដ្ឋាន** ........................................ ៤៨
**អនុសាសន៍** ........................................ ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អារម្ភកថា

រយៈពេលបួនឆ្នាំ នៅក្នុងការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័ស ។ នៅពេលជាមួយគ្នានេះដែរ ការសិក្សាក៏បានឱ្យនិស្សិតគ្រប់រូបទទួលបាននូវចំណេះដឹងថ្មីៗជាច្រើន ក្រោមការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកសាស្ត្រាចារ្យទាំងឡាយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកបានជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសជាតិឱ្យឈានទៅទៅរកវឌ្ឍនភាព និងភាពសម្បូររុងរឿងដូចបណ្តាប្រទេសនានានៅលើពិភពលោក ។

ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់សាស្ត្រាចារ្យ ក៏ដូចជាការបំពេញតំរូវការដ៏ចាំបាច់របស់សាកលវិទ្យាល័យ ដែលតំរូវឱ្យនិស្សិតដែលទទួលបានចំណាត់ថ្នាក់តាមការកំណត់របស់សាកលវិទ្យាល័យ ត្រូវរៀបចំជាសារណា ឬរបាយការណ៍ នៅពេលបញ្ចប់ការសិក្សា និងដើម្បីទុកជាស្នាដៃក៏ដូចជាឯកសារសម្រាប់ប្អូន និស្សិតជំនាន់ក្រោយបានធ្វើការស្រាវជ្រាវបន្ថែម ព្រមទាំងធ្វើយ៉ាងណាមិនឱ្យការសិក្សារយៈពេលបួនឆ្នាំកន្លងទៅដោយឥតប្រយោជន៍ផងនោះ នាងខ្ញុំបានខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព សមត្ថភាព និងចំណេះដឹងដែលបានទទួលកន្លងមក គួបផ្សំនឹងការពិភាក្សា ក៏ដូចជាសុំយោបល់ពីសាស្ត្រាចារ្យមួយចំនួនចុងក្រោយក៏បានសម្រេចនូវរូបរាងក៏ដូចជាសារណានេះឡើង ។

ទោះបីជានាងខ្ញុំខិតខំស្វែងរកនូវឯកសារដ៏សំខាន់ជាច្រើន ដែលទាក់ទងនឹងប្រធានបទនេះមកសរសេររៀបរៀងជាសារណានេះក៏ដោយ ក៏នាងខ្ញុំគិតថាសារណានេះនៅមានចំនុចខ្វះចន្លោះជាពិសេសទៅលើអក្ខរាវិរុទ្ធ និងខ្លឹមសារពុំទាន់បានស៊ីជម្រៅ និងបានត្រឹមត្រូវមួយរយភាគរយនោះទេ។

នាងខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ប្រសិនបើនិស្សិត លោកសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ចូលរួមកែតម្រូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនាក្នុងន័យស្ថាបនា ដើម្បីបំពេញអត្ថន័យអោយកាន់តែស៊ីជម្រៅថែមទៀត។

លើសពីនេះទៅទៀត នាងខ្ញុំសង្ឃឹមថាសារណានេះនឹងក្លាយជាវិភាគទានដ៏សំខាន់បំផុតដល់មិត្តអ្នកអាន ដែលកំពុងសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សា និង ស្ថាប័ននានាទូទាំងព្រះរាជាណាចក្រកម្ពុជា ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ នី សៀវហ៊ុន ជានិស្សិតថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៤ ។

## សូមថ្លែងអំណរគុណ

ចំពោះ **មាតា បិតា** ដែលបានផ្តល់កំណើតសំរាប់ការរស់នៅ និងការសិក្សារបស់កូនរហូតទទួលបានការបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រដោយជោគជ័យ ។ គុណូបការៈរបស់លោកទាំងពីរមានទំហំធំធេងឥតមានរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ មិនតែប៉ុណ្ណោះព្រហ្មវិហារធម៌របស់លោកទាំងពីរធ្វើឱ្យកូនចងចាំជានិច្ចមិនអាចភ្លេចបានឡើយ ។

ចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីទាំងអស់ដែលជាសាស្ត្រាចារ្យបម្រើការងារ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានលះបង់ពេលវេលាព្រមទាំងកំលាំងកាយចិត្ត ដើម្បីបង្ហាត់បង្រៀនដល់នាងខ្ញុំអស់រយៈពេលបួនឆ្នាំ ដើម្បីឱ្យនាងខ្ញុំមានសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់នៅក្នុងប្រទេសព្រមទាំងច្បាប់អន្តរជាតិថែមទៀត ។

ចំពោះលោកសាស្ត្រាចារ្យ **កេត សុជាតិ** ជាសាស្ត្រាចារ្យដឹកនាំក្នុងការសរសេរសារណានេះដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ជួយពន្យល់ណែនាំដល់នាងខ្ញុំក្នុងការសរសេរសារណានេះរហូតបានទទួលជោគជ័យ ។

នាងខ្ញុំសូមថ្លែងអំណរគុណ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតាឥន្ទព្រហ្មជួយឱ្យប្រទេសជាតិរបស់យើងទាំងអស់គ្នាជួបតែសន្តិភាព និងការអភិវឌ្ឍន៍រីកចំរើនឈ្ពោះទៅមុខជានិច្ច និងចាកឆ្ងាយពីសត្រូវឈ្លានពានដែលមានចេតនាទុច្ចរិតចង់បង្ករភាពវឹកវរដល់ភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ ក៏ដូចជាអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាយើងផងដែរ ។

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

តាំងពីសម័យបុរាណកាលរហូតដល់បច្ចុប្បន្នកាលនេះ សង្គមនីមួយៗតែងតែមានការផ្លាស់ប្តូរ មិនថានៅក្នុងសង្គមដែលមានការរីកចំរើន ឬសង្គមដែលមានការអភិវឌ្ឍន៍តិចតួចនោះទេ គឺតែងតែមានការប្រែប្រួល និងវិវឌ្ឍន៍ទោះតិច ឬច្រើននៅតែមាន ។ ទន្ទឹមនឹងការរីកចំរើន ក៏ដូចជាការប្រែប្រួលនៃសង្គមនីមួយៗ បទល្មើសដែលធ្វើឱ្យសង្គមមានភាពល្អក់កករនោះ ក៏មានការផ្លាស់ប្តូរនូវរូបរាង ក៏ដូចជាមានការកកើតឡើងនូវបទល្មើសថ្មីៗបន្ថែមទៀងផងដែរ ។

ហើយសព្វថ្ងៃនេះប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលមានការវិវត្តតិចតួច ក៏មានការប្រែប្រួលផងដែរ។ ហេតុដូច្នេះហើយក៏មានអំពើល្មើសផ្សេងៗ ក៏កើតមានផងដែរ ដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ទៅដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិ កិត្តិយស និងសេចក្តីថ្លៃថ្នូរ និងជាពិសេស គឺប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋទៀតផង ។ បទល្មើសទាំងអស់នេះវាអាចកើតឡើងគ្រប់ទីកន្លែង មិនថានៅទីក្រុង តាមជនបទ តំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនោះទេ វាគ្រាន់តែមានលក្ខណៈខុសគ្នាពាក់ព័ន្ធទៅនឹងចំនួន និងស្ថានភាពនៃបទល្មើសតែប៉ុណ្ណោះ។

ដោយសារតែបានសង្កេតយ៉ាងយកចិត្តទុកដាក់ ឃើញនូវផលវិបាកដែលជះឥទ្ធិពលអាក្រក់ដល់ប្រជាពលរដ្ឋ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរនោះ ទើបប្រទេសកម្ពុជាបានបង្កើតនូវច្បាប់ជាច្រើន ដើម្បីធ្វើការបង្ក្រាប និងដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តបទល្មើសដោយកំណត់ទៅតាមកម្រិតនៃអំពើល្មើសនោះ។ ចំពោះច្បាប់ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រងទៅលើអំពើល្មើសនេះមានច្រើនទៅតាមប្រភេទនៃបទល្មើស ក៏ដូចជាអាស្រ័យទៅតាមវិស័យផ្សេងគ្នា ប៉ុន្តែក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់មួយដែលមានកំណត់អំពីបទល្មើសច្រើនជាងច្បាប់ដទៃទៀត ។

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយធ្វើការបែងចែកជាប្រាំងមួយគន្ថី ហើយគន្ថីទាំងអស់នេះមានគន្ថីចំនួនបី ដែលមានការកំណត់ទៅលើបទល្មើស។ បទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនេះ ត្រូវបានបែងចែកជាបី គឺបទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងបទល្មើសប្រឆាំងនឹងជាតិ។ នៅក្នុង

ចំណោមបទល្មើសទាំងបីប្រភេទនេះ គឺសុទ្ធតែមានលក្ខណៈសំខាន់ទាំងអស់ ប៉ុន្តែបើយើងក្រឡេកមើលទៅបទល្មើសដែលប្រឆាំងនឹងបុគ្គល គឺជាចំណុចដែលគួរឱ្យចាប់អារម្មណ៍ ពីព្រោះវាប៉ះពាល់ទៅដល់បុគ្គលផ្ទាល់តែម្តង។

ចំពោះគន្លីដែលចែងអំពីបទល្មើសប្រឆាំងទៅនឹងបុគ្គល បានកំណត់នូវបទល្មើសជាច្រើនដែលត្រូវបានដាក់ទណ្ឌកម្មតាមក្រមព្រហ្មទណ្ឌ ប៉ុន្តែនៅក្នុងចំណោមបទល្មើសទាំងនោះ បទល្មើសឃាតកម្ម គឺជាបទល្មើសមួយប្រភេទដែលមានលក្ខណៈប៉ះពាល់ដល់បុគ្គលធ្ងន់ធ្ងរជាងគេ គឺប៉ះពាល់ដល់អាយុជីវិតតែម្តង។ ដោយសារតែបទឃាតកម្មមានលក្ខណៈធ្ងន់ធ្ងរ បែបនេះហើយទើបនៅក្នុងបទល្មើសនេះ ក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់លាស់នូវស្ថានទម្ងន់ទោសដែលពាក់ព័ន្ធទៅនឹងបទល្មើសនេះ ។ ស្ថានទម្ងន់ទោសទាំងអស់នៅក្នុងបទល្មើសនេះ វាមានលក្ខណៈដូចទៅនឹងបទល្មើសនេះ ប៉ុន្តែវាគ្រាន់តែបន្ថែមនូវសញ្ញាណថ្មីៗទៅលើបទឃាតកម្មតែប៉ុណ្ណោះ ។

នៅក្នុងសារណានេះ នាងខ្ញុំបានលើកយកនូវបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនដែលមានស្ថានទម្ងន់ទោស មកធ្វើការប្រៀបធៀបគ្នា ពីព្រោះតែវាមានលក្ខណៈស្រដៀងគ្នាច្រើនដែលធ្វើឱ្យមានការច្រឡំទៅលើចំណុចមួយចំនួនរវាងបទល្មើសទាំងពីរនេះ ។ រាល់ភាពមន្ទិលសង្ស័យទាំងឡាយដែលពាក់ព័ន្ធទៅនឹងបទល្មើសទាំងពីរនេះ ត្រូវបានលើកយកមកបកស្រាយនៅក្នុងសារណានេះ។ ការបកស្រាយទៅលើចំណុចនេះត្រូវបានលើកឡើងក្រោមប្រធានបទ***ការប្រៀបធៀបបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន។***

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

មកដល់ពេលនេះ ចំណុចដែលបកស្រាយអំពីប្រភេទទោសក្នុងក្រមទាំងពីរ និងការប្រៀបធៀបបានក្លាយទៅជាចម្ងល់ដ៏សំខាន់មួយសម្រាប់អ្នកសិក្សាស្រាវជ្រាវ ដោយចោទឡើងជាសំនួរថាតើបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនមានលក្ខណៈយ៉ាងដូចម្តេច? ហើយចំនុចដូចគ្នា និងចំណុចខុសគ្នានៃបទល្មើសទាំងពីរមានទៅលើចំណុចណាខ្លះ?

## ៣.កម្មវត្ថុនៃការស្រាវជ្រាវ

កម្មវត្ថុនៃការស្រាវជ្រាវរួមមានដូចបង្ហាញខាងក្រោម÷

- ស្វែងយល់អំពីលក្ខណៈនៃបទល្មើសឃាតកម្ម ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ១៩៩
- ស្វែងយល់អំពីលក្ខណៈនៃបទល្មើសឃាតកម្មគិតទុកជាមុន ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមាត្រា ២០០

- ធ្វើការវិភាគទៅលើបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន រួចហើយទាញនូវចំណុចដូចគ្នា និងចំណុចខុសគ្នានៃបទល្មើសទាំងពីរ
- ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អទៅលើបទល្មើសនីមួយៗ និងការផ្តល់យោបលខ្លះៗចំពោះការអនុវត្តន៍នូវទោសព្រហ្មទណ្ឌទៅលើបទល្មើសទាំងពីរនេះនៅក្នុងពេលបច្ចុប្បន្ន ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការបកស្រាយទៅលើប្រធានបទនេះ នាងខ្ញុំសូមលើកយកមកបកស្រាយតែទៅលើលក្ខណៈនៃបទល្មើសទាំងពីរតែប៉ុណ្ណោះ។ លក្ខណៈនៃបទល្មើសទាំងពីរ គឺបកស្រាយដោយសង្កត់ធ្ងន់ទៅលើនិយមន័យ ធាតុផ្សំនៃបទល្មើសនីមួយៗ និងទោសដែលត្រូវអនុវត្តទៅលើបទល្មើសនោះ ហើយបន្ទាប់មកធ្វើការប្រៀបធៀបរវាងបទល្មើសទាំងពីរដែលមានចំណុចដូច និងចំណុចខុសគ្នា ។ យើងមិនធ្វើការបកស្រាយទៅលើចំណុចមួយចំនួនផ្សេងទៀតទេ ដូចជាការប្រកាសទោសចំពោះបទល្មើសទាំងពីរនេះឡើយ ។

## ៥.គំរោងនៃការស្រាវជ្រាវ

គំរោងនៃការស្រាវជ្រាវនេះបានបែងចែកជា៤ តំណាក់កាលធំៗដូចខាងក្រោម:

- តំណាក់កាលទី១៖រំលឹកឡើងវិញ និងស្វែងយល់បន្ថែមទៅលើទ្រឹស្តីព្រហ្មទណ្ឌទូទៅតាមរយៈឯកសារដែលធ្លាប់បានសិក្សាកន្លងមក និងឯកសារតាមបណ្ណាល័យ និងនៅតាមអ៊ិនធឺណេត។
- តំណាក់កាលទី២: ស្វែងយល់អំពីលក្ខណៈនៃបទល្មើសនីមួយៗ តាមរយៈការសិក្សាទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។
- តំណាក់កាលទី៣: ធ្វើការវិភាគទៅលើការបកស្រាយចំពោះលក្ខណៈនៃបទល្មើសទាំងពីរ ហើយស្វែងរកនូវចំណុចដូច និងចំណុចខុសគ្នាយកមកបង្ហាញ ។
- តំណាក់កាលទី៤៖ ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកនៅក្នុងការកែលម្អទៅលើបទល្មើសនីមួយៗ និងការផ្តល់យោបល់ខ្លះៗចំពោះការអនុវត្តន៍នូវទោសព្រហ្មទណ្ឌចំពោះបទល្មើសទាំងពីរនៅក្នុងពេលបច្ចុប្បន្ន ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីជម្រុញឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ គឺចាំបាច់ទាមទារនូវការសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងការប្រមូលព័ត៌មានដែលពាក់ព័ន្ធសម្រាប់ធ្វើជាមូលដ្ឋានការស្រាវជ្រាវប្រធានបទខាងលើ។ ដូចនេះការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលពី

ប្រភពឯកសារពីរប្រភេទ គឺឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។ តាមលទ្ធភាពជាក់ស្តែងនៃការសិក្សាស្រាវជ្រាវយើងមានវិធីសាស្ត្រប្រមូលព័ត៌មានដូចខាងក្រោមៈ

- **ឯកសារចំបង**
  - ឯកសារដែលបានមកពីច្បាប់ដែលពាក់ព័ន្ធសំខាន់ៗ គឺក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ និងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល។
- **ឯកសារបន្ទាប់បន្សំ**
  - ឯកសារដែលបានមកពី មេរៀនដែលធ្លាប់បានសិក្សាកន្លងមក
  - ឯកសារដែលបានពីសៀវភៅព្រហ្មទណ្ឌទូទៅ
  - ឯកសារដែលបានមកពីការស្រាវជ្រាវតាមអ៊ិនធឺណេត
  - ឯកសារដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ។
  - ឯកសារដែលបានមកពីការណែនាំ ក៏ដូចជាការពិភាក្សាជាមួយសាស្ត្រាចារ្យផ្សេងទៀត

## ៧.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍ដែលទទួលបានពីការស្រាវជ្រាវនេះមានៈ

- **ចំពោះនាងខ្ញុំផ្ទាល់ៈ**
  - ជាភស្តុងតាងដែលបញ្ជាក់ពីលទ្ធផលនឹងស្នាដៃ ដែលបានខិតខំសិក្សាថ្នាក់បរិញ្ញាបត្រអស់រយៈពេល ៤ឆ្នាំ កន្លងមក។
  - ពង្រីក និងបង្កើនូវចំណេះដឹងផ្ទាល់ខ្លួនផ្នែកព្រហ្មទណ្ឌដោយយល់ដឹងទៅលើបទល្មើសដែលមានចែងនៅក្នុងក្រមជាពិសេស ទៅលើបទល្មើសដែលមានលក្ខណៈស្រដៀងគ្នាដែលធ្វើឱ្យមានការពិបាកដល់ការវិភាគ ព្រមទាំងវែកញែកបទល្មើសឱ្យដាច់ចេញពីគ្នា ។
  - ជាស្ពានសំរាប់ឱ្យនាងខ្ញុំអាចសិក្សាបន្តថ្នាក់ឧត្តមសិក្សា។
- **ចំពោះសាធារណៈជនៈ**
  - ជាប្រភពព័ត៌មានបន្ថែមសំរាប់ការស្វែងយល់អំពីក្រមព្រហ្មទណ្ឌ ជាពិសេសទាក់ទងទៅនឹងបទល្មើសតែម្តង ដល់សាធារណៈជន មិត្តនិសិត្សទាំងឡាយ និងនិសិត្សជំនាន់ក្រោយៗ។
  - ជាប្រភពព័ត៌មានមួយសំរាប់ស្វែងយល់ពីចំណុចដូច និងចំណុចខុសគ្នានៃបទល្មើសទាំងពីរ ដែលបង្ហាញឱ្យឃើញនូវចំណុចសំខាននៃបទល្មើសទាំងពីរដែលយើងពិបាកធ្វើការបែងចែក ។

## ៨.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវចែកចេញជា៣ជំពូកដូចជា:

- **សេចក្តីផ្តើម**
- **ជំពូកទី១** បទឃាតកម្ម
- **ជំពូកទី២** :បទឃាតកម្មគិតទុកជាមុន
- **ជំពូកទី៣** :ការប្រៀបធៀបបទល្មើសទាំងពីរ
- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**
- **ឧបសម្ព័ន្ធ**
- **ឯកសារយោង**

# ជំពូកទី ១
# បទឃាតកម្ម

បទឃាតកម្ម គឺជាបទល្មើសមួយដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិដាច់ខាតធំបំផុតរបស់មនុស្សគឺ "សិទ្ធិរស់រានមានជីវិត" ។ សិទ្ធិជាសារវន្តនេះ មានចែងនិងការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងដោយអត្ថបទអន្តរជាតិដ៏ទៃផ្សេងទៀតជាពិសេស គឺសេចក្តីថ្លែងការណ៍ជាសាកល ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ ។ យោងតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។" សិទ្ធិរស់រានមានជីវិតនេះមិនត្រឹមតែបានទទួលស្គាល់ទៅដល់ប្រជាពលរដ្ឋគ្រប់រូបទេ សូម្បីតែឧក្រិដ្ឋជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក៏ទទួលបាននូវសិទ្ធិនេះដែរ ។ ហេតុដូច្នេះហើយ បានជាទោសប្រហារជីវិតនេះត្រូវបានលុបចោល[1]។ បទឃាតកម្ម ត្រូវបានច្បាប់ចាត់ទុកជាប្រភេទ នៃបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ ។

## ១.១.និយមន័យនៃបទឃាតកម្ម

បទឃាតកម្ម គឺជាអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះដោយប្រើអាវុធក្តី ឬមិនប្រើអាវុធក្តី[2] ។ ពាក្យថា "សម្លាប់" នេះមានន័យថាធ្វើឱ្យស្លាប់ (អស់ជីវិត) បំបាត់ជីវិត ឬផ្តាច់ជីវិត[3]។ ដូចនេះ យើងអាចយល់បានថា បទឃាតកម្ម គឺជាអំពើធ្វើឱ្យមនុស្សបាត់បង់ជីវិតដោយចេតនា ឬអំពើផ្តាច់ជីវិតមនុស្សដោយចេតនា ទោះបីជាប្រើអាវុធ ឬមិនប្រើអាវុធក៏ដោយ ។

ម្យ៉ាងទៀត បទឃាតកម្ម គឺអំពើដែលសម្លាប់ ឬធ្វើឱ្យផ្តាច់ជីវិតរបស់ជនរងគ្រោះ ទោះបីជាធ្វើឡើងដោយមានអាវុធក្តី ឬគ្មានអាវុធក្តី គឺស្តែងចេញតាមគ្រប់រូបភាព និងតាមគ្រប់មធ្យោបាយ ។ ឯអ្នកខ្លះ គឺប្រព្រឹត្តអំពើដោយដៃទទេ អត់មានប្រើអាវុធទេ និងអ្នកខ្លះប្រើអាវុធ។ តើពាក្យអាវុធសំដៅទៅលើអ្វី? បើយើងពិនិត្យទៅលើមាត្រា ៨១ នៃក្រមព្រហ្មទណ្ឌ គឺមានចែងនូវពាក្យថាអាវុធដូចខាងក្រោម ៖

[1] មាត្រា ៣២ នៃ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[2] សន្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ លេខរៀង ទី៦៨

[3] វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧

*"អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស។ ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ ៖*

*១-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង ។*

*២-វត្ថុមានទិសដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ។*

*ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែងត្រូវចាត់ទុកដូចបាន ប្រើប្រាស់អាវុធដែរ។"*

វត្ថុនៅក្នុងមាត្រានេះ អាចជាវត្ថុរឹង វត្ថុរាវ ឬឧស្ម័ន ។ តើអ្វីទៅជាវត្ថុរាវ ? គឺមានដូចជាថ្នាំពុល ទឹកអាស៊ីត ឬឧស្ម័នពុល ដូចជាថ្នាំបាញ់មូស យកទៅបាញ់ចូលច្រមុះរហូតទាល់ តែពុលស្លាប់ ទាំងអស់នេះ គឺចាត់ចូលអាវុធដូចគ្នា ។ អញ្ចឹងអាវុធនេះ គឺទាក់ទងជាមួយនឹងវត្ថុទាំងអស់។ ហើយមួយទៀត គឺសត្វ បើអ្នកដែលប្រើសត្វទៅសម្លាប់ដូចជាបញ្ជាសត្វខ្លា ឬសត្វឆ្កែឱ្យទៅខាំគេរហូតដល់ស្លាប់ ។

<u>**ចំណាំ**</u> ៖ សូមកុំច្រឡំថាអ្នកដែលបញ្ជាឆ្កែហ្នឹង គឺជាអ្នកផ្តើមគំនិតទោះបើតាមក្រមនេះ គឺមានអ្នកណាដែលបញ្ជា គឺជាអ្នកផ្តើមគំនិត ហើយអ្នកប្រព្រឹត្តដោយផ្ទាល់ គឺចារី ។ ស្រាប់តែដាក់ថាឆ្កែ គឺជាចារីនៅក្នុងបទឃាតកម្ម ឯមនុស្សជាអ្នកបញ្ជាឆ្កែ គឺជាអ្នកផ្តើមគំនិតនៅក្នុងបទឃាតកម្ម ។ គឺមិនមែនដូច្នេះទេ បើយោងតាមមាត្រា ៨១ ខាងលើនេះផ្ទុយទៅវិញគឺ ៖

អ្នកដែលបញ្ជាឆ្កែនៅទីនេះ គឺជាចារី ហើយឆ្កែដែលទៅខាំគេឱ្យស្លាប់ហ្នឹង គឺជាអាវុធនេះ គឺចូលអំពើឃាតកម្មដោយប្រើអាវុធ។ ខ្លះទៀត គឺធ្វើដោយប្រើថ្នាំពុល ឬ អំពើឃាតកម្មមានការពួនស្ទាក់ មានការរៀបចំគម្រោងគិតទុកជាមុន ។ ដូច្នេះសកម្មភាពជាសត្យានុម័តនេះ គឺថាអាចធ្វើឡើងដោយមានការរៀបចំគម្រោងគិតទុកជាមុន ឬក៏មានការពួនស្ទាក់។

## ១.២.ធាតុផ្សំនៃបទឃាតកម្ម

នៅក្នុងធាតុផ្សំនៃបទល្មើសនេះ យើងនឹងលើកនូវធាតុផ្សំសំខាន់ៗទាំងបីនៃបទល្មើសឃាតកម្មគឺ (**១.២.១ ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម**),(**១.២.២ ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម**) និង (**១.២.៣ ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម**) ដែលមានខ្លឹមសារលម្អិតទាំងស្រុងដូចខាងក្រោម ៖

### ១.២.១.ធាតុផ្សំនីត្យានុកូលនៃបទឃាតកម្ម

ធាតុផ្សំនីត្យានុកូល ឬយើងហៅម្យ៉ាងទៀតថា ធាតុច្បាប់ គឺសំដៅទៅលើការចែងអំពីលក្ខខណ្ឌនៃបទល្មើសដែលមានចែងនៅក្នុងច្បាប់ជាធរមាន ហើយខាងក្រោមនេះ គឺជាលក្ខខណ្ឌបឋមនៃការកំណត់អំពីបទឃាតកម្មតាមក្រមខ្មែរថ្មី។

**១.២.១.១. ក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩**

បទឃាតកម្មមានចែងនៅក្នុងមាត្រា ១៩៩ ឥឡូវយើងសូមពិនិត្យទាំងអស់គ្នាទៅលើក្រមព្រហ្មទណ្ឌថ្មី ។ យោងទៅតាមមាត្រា ១៩៩ គេឱ្យអត្ថន័យនៃការធ្វើឃាតកម្មនេះថាជា *"អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើ វំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម ។ ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ** ។"*

នៅក្នុងក្រមថ្មីយើងនេះ បានប្រើពាក្យថាឃាតកម្ម គឺសំដៅទៅលើអំពើសម្លាប់មនុស្សដោយចេតនា។ ពីមុនយើងមានចែងពី "មនុស្សឃាតដោយចេតនា, ប៉ុនប៉ងសម្លាប់ដោយចេតនា ឃាតកម្មគិតទុកជាមុន" តែឥឡូវទាក់ទងជាមួយអំពើសម្លាប់មនុស្សដោយចេតនា គឺយើងប្រើពាក្យ "ឃាតកម្ម" ទាំងអស់ ។ អត់មានពាក្យថាឃាតកម្មផ្សេង ឯសម្លាប់មនុស្សផ្សេង ឬក៏មនុស្សឃាតដោយចេតនាផ្សេងនោះទេ គឺអត់មានប្រើពាក្យនេះទៀតទេ តែយើងប្រើពាក្យឃាតកម្មហ្នឹង គឺសំដៅទៅលើអំពើសម្លាប់មនុស្សដោយចេតនា។ អត្ថន័យរបស់វា គឺអំពើសម្លាប់មនុស្សដោយចេតនាតាមគ្រប់មធ្យោបាយ ទោះបីជាប្រើអាវុធក៏ដោយ មិនប្រើអាវុធក៏ដោយ ឱ្យតែសម្លាប់មនុស្សចេញពីឆន្ទៈរបស់ជនល្មើស គឺគាត់ចង់ផ្តាច់ជីវិតរបស់មនុស្ស វាជាឃាតកម្មទាំងអស់។

**១.២.១.២. ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល**

នៅមុនពេលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទាំងស្រុង បទឃាតកម្ម ឬអំពើមនុស្សឃាតដោយចេតនាត្រូវបានចែងផ្តន្ទាទោសដោយមាត្រា ៣២ ក្នុងមាតិកាទី ៤ ស្តីពីបទឧក្រិដ្ឋ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ដែលមាត្រានេះត្រូវបានកែប្រែដោយច្បាប់ស្តីពី " ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ " ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២។ មាត្រា ៤ នៃច្បាប់ស្តីពីវិសោធនកម្មក្រោយ នេះបានចែងថា "ជនណាដែលបានសម្លាប់មនុស្សដោយចេតនា ឬប៉ុនប៉ងសម្លាប់ជនណាដោយចេតនា ដោយគ្មានស្ថានទម្ងន់ទោសដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬ មិនបានប្រើអាវុធក្តីត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ ទៅ ១៥ ឆ្នាំ។"

ទាំងអស់ខាងលើ គឺជាធាតុផ្សំនីត្យានុកូល ឬជាធាតុច្បាប់ដែលយើងព្យាយាមបង្ហាញទាំងនៅក្នុងច្បាប់ចាស់ និងច្បាប់ថ្មី។ ក៏ប៉ុន្តែចាប់ពីពេលនេះទៅ សូមអ្នកអានទាំងអស់មេត្តាផ្តោតអារម្មណ៍សិក្សាភាគច្រើនតែទៅលើក្រមព្រហ្មទណ្ឌថ្មីត្រង់មាត្រា ១៩៩ ទៅបានហើយ ។

### ១.២.២-ធាតុផ្សំសត្យានុម័តនៃបទឃាតកម្ម

ឥឡូវយើងពិនិត្យមើលអំពីធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈនៃបទល្មើសឃាតកម្ម និង លក្ខខណ្ឌសំខាន់ៗនៃធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈនៅក្នុងបទល្មើសនេះដូចតទៅ ៖

#### ១.២.២.១. អំពើសម្លាប់មនុស្ស ឬអំពើផ្តាច់ជីវិតមនុស្ស ឬអំពើប្រល័យជីវិតមនុស្ស

បទឃាតកម្ម ឬជាបទល្មើសមនុស្សឃាតដោយចេតនា គឺជាប្រភេទបទល្មើសសកម្ម ដូចនេះ អំពើសម្ភារៈនៃបទល្មើសនេះ ត្រូវស្តែងឡើងក្រោមរូបភាពជាអំពើសម្ភារៈជាវិជ្ជមាន។ និយាយម្យ៉ាងទៀត អំពើសម្លាប់មនុស្សនេះត្រូវស្តែងឡើងជាកាយវិការបង្ហាញមកខាងក្រៅតាម រយៈអំពើជាសម្ភារៈមួយ ឬច្រើន។ អំពើសំភារៈនេះ អាចជាអំពើមួយដាច់តែឯង ឬក៏ជាអំពើសម្ភារៈ ច្រើនរួមគ្នាដែលបណ្តាលឱ្យជនដ៏ទៃស្លាប់ ឬក៏អាចត្រឹមតែបណ្តាលឱ្យជនដ៏ទៃរបួសធ្ងន់ប៉ុណ្ណោះ ព្រោះថាអំពើមនុស្សឃាតដោយចេតនា គឺជាបទឧក្រិដ្ឋដែលការប៉ុនប៉ង ប្រព្រឹត្តអំពើនេះក៏ត្រូវផ្តន្ទា ទោសដូចគ្នានឹងបទល្មើសបានសម្រេចដែរ ។ អំពើសម្ភារៈនេះ អាចស្តែងឡើងតាមគ្រប់មធ្យោបាយ ទាំងអស់ដូចជា ការវាយរហូតដល់ស្លាប់ ការសម្លាប់ ដោយបំពុល ដោយការប្រើប្រាស់អាវុធ ដោយ ការប្រើខ្សែរឹតក ដោយឆក់នឹងចរន្តអគ្គិសនី ឬដោយប្រើប្រាស់រថយន្តជាដើម។ ល ។ ប៉ុន្តែប្រសិនបើ ការប្រព្រឹត្តអំពើសម្លាប់មនុស្ស ដោយចេតនា ធ្វើឡើងក្រោមរូបភាពមួយឃោរឃៅ ឬក្រោមរូបភាព ជាទារុណកម្មនោះ អំពើទាំងនេះនឹងក្លាយទៅជាស្ថានទម្ងន់ទោសនៃអំពើមនុស្សឃាតដោយចេតនា ផងដែរ ។

#### ១.២.២.២.លក្ខណៈសម្បត្តិនៃជនរងគ្រោះ

ទាក់ទងនឹងជនរងគ្រោះ យើងសាកល្បងបង្ហាញនូវលក្ខណៈសម្បត្តិចំនួន ០៣ (បី) គឺ ៖

-ជនរងគ្រោះ ត្រូវតែកើតចេញពីផ្ទៃម្តាយមកហើយនៅមានជីវិត

-ជនរងគ្រោះ ត្រូវតែជាអ្នកដទៃយ៉ាងដាច់ខាត និងក្រៅពីជនល្មើស

-ជនរងគ្រោះ ត្រូវតែជាជនដែលរស់រានមានជីវិត ។

##### ក. ត្រូវតែកើតចេញពីផ្ទៃម្តាយមកហើយនៅមានជីវិត

ដើម្បីឱ្យចូលទៅក្នុងធាតុផ្សំនៃអំពើឃាតកម្ម គឺថាត្រូវមានជនរងគ្រោះមានន័យថាជនរង គ្រោះ គឺជាមនុស្សដែលកើតចេញពីផ្ទៃម្តាយមកហើយមានជីវិត គឺទាល់តែកើតចេញមកក្លាយទៅជា មនុស្សមុនសិន ទោះបីជាកើតមកភ្លាមគេហៅគាត់ថាជាទារកក៏ដោយ។

ដូច្នេះទាល់តែមានកើតចេញពីផ្ទៃម្តាយមកហើយ គាត់នៅរស់គឺគាត់មានជីវិត ហើយយើង ទៅសម្លាប់ អាហ្នឹងបានប្រព្រឹត្តនូវអំពើឃាតកម្ម ដូចជាពេលកើតមកទារកនោះនៅរស់តែមានអ្នក

ទៅច្របាច់ក៏ទារកនោះ ឬ ទៅជ្រមុចទឹកទារកនោះឱ្យស្លាប់ នេះគឺជាឃាតកម្ម។ អញ្ចឹងលក្ខខណ្ឌទី ១ គឺត្រូវមានជនរងគ្រោះដែលកើតចេញពីផ្ទៃម្តាយមកមានជីវិត ។

**<u>ចំណាំ</u>** ៖ តែបើមិនទាន់ចេញមកពីផ្ទៃម្តាយផង ដូចជារំលូតទារកក្នុងផ្ទៃ នោះអត់មែនជាអំពើឃាតកម្មទេ។ ចំណុចនេះ គឺយើងត្រូវទៅអនុវត្តតាមច្បាប់ ស្តីពីការរំលូតកូនវិញ។

**ខ. ត្រូវតែជាអ្នកដទៃ ក្រៅពីជនល្មើសជាដាច់ខាត**

អ្នកដទៃនៅទីនេះ គឺមិនមែនខ្លួនឯងនោះទេ ប្រសិនបើធ្វើការសម្លាប់ខ្លួនឯង ឬ មួយធ្វើអត្តឃាតខ្លួនឯង គឺមិនចូលជាបទឃាតកម្មទេ។

<u>ឧទាហរណ៍</u> ៖ **ក** យល់ឃើញថាខ្លួនអស់សង្ឃឹមក្នុងជីវិតហើយ មិនដឹងថារស់នៅធ្វើអីទៀត រួចក៏យកថ្នាំពុលមកផឹកសម្លាប់ខ្លួនឯងទៅ។ ដល់ពេលគាត់អត់ស្លាប់ ស្រាប់តែយើងទៅចាប់គាត់ដោយចោទពី "បទប៉ុនប៉ងឃាតកម្ម" បើយោងតាមមាត្រាលើនេះ គឺអត់មែនជាបទឃាតកម្មទេ ពីព្រោះវាគឺជាជីវិតរបស់ខ្លួនឯង។ ដូច្នេះនៅក្នុងការដែលសម្លាប់ជនរងគ្រោះនេះ គឺទាល់តែជនរងគ្រោះនោះគឺជាអ្នកដទៃ។ ហើយពាក្យថាជនរងគ្រោះ ជាអ្នកដទៃហ្នឹង គឺសំដៅទៅលើអ្នកណាដែលក្រៅពីខ្លួនឯង តែសូមកុំទៅច្រឡំថាក្រៅពីសាច់ញាតិមិនមែនទេ អ្នកណាក៏ដោយ ជីដូនជីតាក៏ដោយ ឪពុកម្តាយក៏ដោយ សហព័ទ្ធក៏ដោយ កូនចៅក៏ដោយ។ ល ។ ឱ្យតែមិនមែនជាខ្លួនឯងឬក្រៅពីខ្លួនឯងគឺជាអ្នកដទៃទាំងអស់ ហើយដែលនៅក្នុងអត្ថន័យច្បាប់ គឺជនរងគ្រោះជាអ្នកដទៃជាដាច់ខាត។ ជាងនេះទៅទៀត ប្រសិនបើជនរងគ្រោះ គឺជាកូនចៅ ឪពុកម្តាយ ឬតាយាយរបស់ជនល្មើស លក្ខណៈសម្បត្តិរបស់ជនរងគ្រោះប្រភេទនេះ គឺជាស្ថានភាពទូទៅដែលចៅក្រមតែងតែលើកយកមកធ្វើការពិចារណាដើម្បីធ្វើការកំណត់អំពីទណ្ឌកម្ម ដែលត្រូវផ្តន្ទាទោសទៅលើជនល្មើសនោះ ។

**គ. ត្រូវតែជាមនុស្សដែលរស់រានមានជីវិត**

ចុះហេតុដូចម្តេចបានជា ខ្ញុំលើកពីបញ្ហារស់រានមានជីវិត? ឧបមាថាជាសាកសព ជនម្នាក់ស្លាប់ហើយ ម្យ៉ាងទៀតជនល្មើសដឹងថាស្លាប់ ហើយពោលថាមកមិនទាន់ អានេះស្លាប់បាត់ រួចគាត់ក៏ទាញកាំភ្លើងទៅដល់បាញ់ជនដែលជាសាកសពនោះចំនួន ២ គ្រាប់ទៅ សួរថាតើអំពើដែលគាត់បាញ់សាកសពនេះ ជាអំពើឃាតកម្មដែរ ឬទេ? ជាចម្លើយ គឺអត់ទេ ពីព្រោះឃាតកម្ម ចេតនារបស់ជនល្មើសចង់ផ្តាច់ជីវិតជនរងគ្រោះ ចុះបើជនរងគ្រោះដាច់ជីវិតបាត់ទៅហើយ ឥឡូវទៅធ្វើឃាតកម្មយ៉ាងម៉េចទៀត? តែអំពើនេះ គឺចូលបទល្មើសផ្សេងមួយទៀត គឺ"បទប៉ះពាល់ដល់បូរណភាពសាកសព" វិញ។ ពីព្រោះវាទាក់ទងជាមួយនឹង ការគោរពបូជា និងជាអំពើមួយដែលប៉ះពាល់ដល់ស្មារតីរបស់ជនទាំងឡាយដែលនៅរស់។ អញ្ចឹងអំពើនេះមិនមែនជាអំពើឃាតកម្មទេ។ ប៉ុន្តែរឿង

មួយទៀត ខ្ញុំលើកជា*ឧទាហរណ៍*ថា៖ **ក** ចង់សម្លាប់ **ខ ហើយ**គាត់ដឹងថា **ខ** នៅផ្ទះថ្ងៃហ្នឹងគាត់ឡើងទៅដល់ក៏បាញ់ **ខ ប៉ុន្តែ ខ មុននឹង ក បាញ់ហ្នឹងគឺ ខ** ដាច់ខ្យល់ស្លាប់ដោយសារខ្យល់គរមុនប្រហែលជា ១ម៉ោង រួចហើយ ប៉ុន្តែ **ក** អត់ដឹងថា **ខ** ស្លាប់ទេ ដោយឡើងទៅដល់ក៏បាញ់ផ្ទង១ទៅតែ **ខ** ស្លាប់បាត់ទៅហើយ និងស្លាប់តាំងពីមុនពេលដែល **ក** ទៅបាញ់នោះទៀត។ សួរថាតើអំពើនេះយ៉ាងម៉េចដែរ? ពីព្រោះក្រោយធ្វើកោសល្យវិច័យឃើញថា ការស្លាប់របស់ **ខ** ហ្នឹងមិនមែនដោយសារតែការបាញ់របស់ **ក** ទេ គឺដោយសារខ្យល់គរ ឬ ដោយសារស្ថានភាពកាលៈទេសៈផ្សេងទៀត តើអំពើដែល **ក** បាញ់ **ខ** នេះជាអំពើឃាតកម្មដែរ ឬទេ? ចម្លើយពិតប្រាកដនោះ គឺជាអំពើ "ប៉ុនប៉ងឃាតកម្ម" ព្រោះការប្រព្រឹត្តបទល្មើសរបស់ **ក** មិនបានសម្រេចដោយសារកត្តាក្រៅឆន្ទៈផ្សេងទៀតមករារាំង មានន័យថា **ក** ទៅសម្លាប់ **ខ** គាត់អត់ដឹងថា **ខ** ស្លាប់ទៅហើយទេ តែបើដឹងថា **ខ** ស្លាប់គាត់នៅតែបាញ់នេះ គឺជាអំពើប៉ះពាល់ដល់បូរណភាពសាកសពវិញ ប៉ុន្តែរឿងនេះ គឺ **ក** នៅតែគិតថា **ខ** នៅរស់ ដូច្នេះអំពើដែលគាត់បាញ់នេះ គឺជាអំពើឃាតកម្មវាអាស្រ័យទៅលើធាតុផ្សំអត្តនោម័ត ឬ ធាតុចេតនាមួយទៀត។ សួរថា តើគាត់ដឹងទេនៅអំពើរបស់គាត់ថា នៅពេលដែលគាត់បាញ់តើជននោះស្លាប់ហើយ ឬនៅ? ក្នុងចិត្តគាត់ គឺនៅតែគិតថាជននោះអត់ទាន់ស្លាប់ ឬជាជនដែលនៅមានជីវិត។ អញ្ចឹងអំពើនេះ នៅតែជាអំពើឃាតកម្មដដែល។

ជនរងគ្រោះ អាចជាមនុស្សគ្រប់ប្រភេទ ហើយជនរងគ្រោះអាចមិនត្រូវបានគេស្គាល់អត្តសញ្ញាណ ឬមួយក៏សាកសពរបស់ជនរងគ្រោះអាចមិនត្រូវបានគេរកឃើញ។ ប៉ុន្តែអ្វីដែលសំខាន់ដើម្បីឱ្យអំពើនោះ ត្រូវបានគេចាត់ទុកថាជាអំពើមនុស្សឃាតដោយចេតនាបាននោះ គឺគេត្រូវបង្ហាញឱ្យឃើញថាជនរងគ្រោះ គឺជាមនុស្សដែលនៅរស់រានមានជីវិតនៅពេលដែលមានអំពើសម្លាប់ ឬប្រល័យជីវិតមនុស្សកើតឡើង។ ការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះ ទោះបីជាជនរងគ្រោះកំពុងទទួលរងនូវការឈឺចាប់ ហើយអាចរស់នៅមានជីវិតបានតែប៉ុន្មាននាទីទៀតក៏ដោយ ក៏គេចាត់ទុកថាអំពើនោះ ជាអំពើមនុស្សឃាតដោយចេតនា ដែលត្រូវផ្តន្ទាទោសផងដែរ។

ដូច្នេះហើយ ពេលខ្លះការតម្រូវឱ្យជនរងគ្រោះមានជីវិតនៅពេលដែលមានអំពើសម្លាប់ មនុស្សគឺពុំមែនជាលក្ខខណ្ឌចាំបាច់ដាច់ខាត ដើម្បីធ្វើការផ្តន្ទាទោសជនល្មើសឡើយ។ ជាគោលការណ៍គេធ្វើការផ្តន្ទាទោសចំពោះអំពើសម្លាប់ ឬប្រល័យជីវិតមនុស្សដែលធ្វើទៅលើសាកសព (ដូចជាការបាញ់ប្រហារទៅលើសាកសព ដោយស្មានថាជាជនដែលនៅរស់រានមានជីវិត) ប៉ុន្តែពុំមែនឈរលើមូលដ្ឋាននៃអំពើមនុស្សឃាតដោយចេតនាបានសម្រេចនោះទេ គឺផ្អែកលើមូលដ្ឋាន នៃការប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាទៅវិញ។ យោងតាមទ្រឹស្តីនេះ គេមិនអាចចាត់ទុកថាមានអំពើមនុស្ស

ឃាតបានសម្រេចកើតនោះទេ ពីព្រោះថានៅពេលមានអំពើសម្លាប់ ឬ ប្រល័យជីវិតមនុស្ស ជនរងគ្រោះពុំមែនជាមនុស្សមានជីវិតទេ ប៉ុន្តែជាសាកសពទៅវិញ។ ប៉ុន្តែការស្លាប់មុនអំពើប្រល័យជីវិតមនុស្ស ជាកាលៈទេសៈមួយដែលស្ថិតនៅក្រៅឆន្ទៈរបស់ចារីនៃបទល្មើស ហើយអំពើសម្លាប់ ឬ ប្រល័យជីវិតមនុស្សនោះ គឺជាអំពើដែលត្រូវបានគេចាត់ទុកថា ជាការចាប់ផ្តើមប្រព្រឹត្តបទល្មើស ដែលជាលក្ខខណ្ឌមួយនាំឱ្យអំពើនោះក្លាយទៅជាអំពើប៉ុនប៉ង ដែលត្រូវមានទោស ឬ (បទល្មើសប៉ុនប៉ង) នេះបើយោងទៅតាមបញ្ញត្តិនៃមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

**១.២.៣.ធាតុផ្សំអត្តនោម័តនៃបទឃាតកម្ម**

បើយោងទៅតាមក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៩ យើងឃើញថាធាតុផ្សំអត្តនោម័ត នៃបទឃាតកម្មមានករណីបីចំបងៗ គឺករណីទី១-មានចេតនាចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ ករណីទី២-មានការយល់ព្រមពីជនរងគ្រោះ និង ករណីទី៣-ការការពារស្របច្បាប់និងច្រឡំ។

**១.២.៣.១. ករណីមានចេតនាចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះ**

ចំពោះធាតុចេតនានៃអំពើឃាតកម្ម គឺជនល្មើសចង់ផ្តាច់យកជីវិតរបស់ជនរងគ្រោះមានន័យថាចង់ឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតពីលើលោកនេះតែម្តង។ យើងអាចបន្ថែមទៀតថា ធាតុផ្សំអត្តនោម័តនៃអំពើមនុស្សឃាតដោយចេតនា គឺសំដៅលើចេតនារបស់ចារីនៃបទល្មើសក្នុងការផ្តល់សេចក្តីស្លាប់ដល់ជនរងគ្រោះ។ ធាតុចេតនាសម្លាប់មនុស្សនេះ គឺជាធាតុសំខាន់បំផុតដែលអាចឱ្យគេធ្វើការបែងចែកអំពើមនុស្សឃាតដោយចេតនា ចេញពីបទល្មើសផ្សេងៗទៀតដែលអាច បណ្តាលឱ្យមានលទ្ធផលដូចគ្នា គឺការបាត់បង់ជីវិតមនុស្ស ដូចជាអំពើមនុស្សឃាតដោយ អចេតនាជាដើម។ ម្យ៉ាងទៀត ចម្លើយសារភាពរបស់ចារីដែលជាទូទៅកម្រមាននេះ គឺគ្រាន់តែអាចជាតម្រុយក្នុងការកំណត់ចេតនាទុច្ចរិតចង់សម្លាប់ជនរងគ្រោះ។ ដូចនេះជាទូទៅចៅក្រមត្រូវធ្វើ សេចក្តីសន្និដ្ឋាននូវធាតុចេតនាទុច្ចរិតនេះ ដោយធ្វើការពិចារណាទៅលើមូលហេតុនៃការប្រព្រឹត្តរបស់ជនល្មើស ឬធ្វើការវាយតម្លៃទៅលើកាលៈទេសៈផ្សេងៗដែលនៅជុំវិញសកម្មភាពល្មើស ឬមរណភាពរបស់ជនរងគ្រោះដូចជា ៖

- អាវុធប្រើប្រាស់ ៖ កាំភ្លើង
- ពហុភាពនៃការកាប់ ចាក់ វាយដំ
- ពហុភាពនៃរបួសចំកន្លែងស្លាប់
- មូលហេតុនៃការប្រព្រឹត្តបទល្មើសជាដើម។ល។

ម្យ៉ាងទៀត ការកំណត់ធាតុចេតនារបស់ជនល្មើសតាមរយៈការសន្មត់ ឬសច្ចធារណ៍ទាំងអស់នេះ គឺជាអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមទាំងស្រុង។ ដូចនេះ ចៅក្រមអាចសន្មត់ថាមានចេតនាសម្លាប់មនុស្សហើយ នៅពេលដែលចារីនៃបទល្មើសបានដឹងថាអំពើរបស់ខ្លួននោះនឹងបណ្ដាលឱ្យជនរងគ្រោះស្លាប់។ ប៉ុន្តែបញ្ហាអាចចោទឡើង ព្រោះថាការសន្មត់ ដូច្នេះអាចនាំឱ្យយើងធ្វើការបែងចែករវាងចេតនា ឬក៏ឆន្ទៈសម្លាប់មនុស្ស និងការដឹងរបស់ជនល្មើសអំពីផលវិបាកនៃអំពើរបស់ខ្លួនថានឹងបណ្ដាលឱ្យមានការបាត់បង់ជីវិតរបស់ជនរងគ្រោះ។ ជាគោលការណ៍ ចេតនាសម្លាប់មនុស្ស គឺមិនត្រឹមតែទាញចេញពីឆន្ទៈរបស់ជនល្មើសក្នុងការចង់ទទួលបានលទ្ធផលនៃអំពើរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាញចេញពីការដឹងជាមុនរបស់ជនល្មើសអំពីផលវិបាកដែលនឹងកើតឡើងដោយសារអំពើរបស់ខ្លួនទៀតផង។

**១.២.៣.២. ករណីមានការយល់ព្រមពីជនរងគ្រោះ**

ការយល់ព្រមពីជនរងគ្រោះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយលើកលែងតែច្បាប់ចែងផ្សេងពីនេះ។ ដូចនេះ វេជ្ជបណ្ឌិតដែលយល់ព្រមចាក់ថ្នាំសម្លាប់តាមការទទូចស្នើសុំរបស់អ្នកជម្ងឺ ដែលទទួលរងការឈឺចាប់យ៉ាងខ្លាំងបណ្ដាលមកពីជម្ងឺមហារីករាំរ៉ៃរបស់គាត់ដែលមិនអាចព្យាបាលបាន មិនអាចរួចផុតពីការចោទប្រកាន់ និងផ្ដន្ទាទោសព្រហ្មទណ្ឌពីតុលាការឡើយ ប៉ុន្តែចៅក្រមក៏អាចធ្វើការពិចារណាទៅលើកាលៈទេសៈនេះ ដើម្បីផ្ដល់ការសម្រាលទោសដល់ជនល្មើសបានផងដែរ។ ដូចនេះវៀរលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ មូលហេតុនៃបទល្មើស គឺពុំអាចលុបចោលនូវចេតនាសម្លាប់មនុស្ស និងអំពើមនុស្សឃាតដោយចេតនាបានឡើយ។

**១.២.៣.៣. ករណីនៃការការពារស្របច្បាប់ និង ករណីមានការភ័ន្តច្រឡំ**

ការសម្លាប់មនុស្សដោយការការពារស្របច្បាប់ ឬការការពារជាធម្មានុរូប ដោយមានលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់ គឺអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែការភ័ន្តច្រឡំលើជនរងគ្រោះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងតែការភ័ន្តច្រឡំមួយចំនួនប៉ុណ្ណោះ ដែលអាចនាំឱ្យជនល្មើសរួចផុតពីការចោទប្រកាន់ និងការផ្ដន្ទាទោសពីបទឃាតកម្ម ឬ បទមនុស្សឃាតដោយចេតនាដែលជំនួសដោយអំពើមនុស្សឃាតដោយអចេតនាវិញ។

ឧទាហរណ៍ៈដូចជាជនម្នាក់បានបាញ់សំដៅសត្វ ដោយគិតថាជាសត្វតែបែរជាទៅបាញ់ត្រូវជនម្នាក់បណ្ដាលឱ្យស្លាប់ទៅវិញ (ចេតនាទុច្ចរិត នៅក្នុងអំពើនេះគេឱ្យឈ្មោះថាជាចេតនាទុច្ចរិតជាយថាហេតុនៅក្នុងករណីនេះ ជនល្មើសត្រូវទទួលខុសត្រូវចំពោះកំហុសអចេតនាតែប៉ុណ្ណោះ)។

## ១.៣.ទោសដែលត្រូវទទួលរងនៃបទឃាតកម្ម

ទោសដែលត្រូវទទួលរងនៃបទឃាតកម្មមានពីរករណី (១.៣.១) ករណីគ្មានស្ថានទម្ងន់ទោស និង ( ១.៣.២ ) ករណីមានស្ថានទម្ងន់ទោស។

### ១.៣.១. ករណីគ្មានស្ថានទម្ងន់ទោស

សម្រាប់អំពើឃាតកម្មនេះ ប្រសិនគ្មានស្ថានទម្ងន់ណាមួយទេ គឺត្រូវទទួលទោសទៅតាមបញ្ញត្តិមាត្រា ១៩៩ គឺ*ដាក់ពន្ធនាគារពី **១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ*** ។

### ១.៣.២.ករណីមានស្ថានទម្ងន់ទោស

ប្រសិនបើប្រព្រឹត្តបទឃាតកម្មរួចហើយ ថែមទាំងបានបំពេញនូវលក្ខខណ្ឌណាមួយដែលមានចែងចាប់ពីមាត្រា ២០០ ដល់មាត្រា ២០៥ នោះជនល្មើសនឹងត្រូវទទួលនូវស្ថានទម្ងន់ទោសដូចខាងក្រោម ៖

#### ១.៣.២.១. បទឃាតកម្មគិតទុកជាមុន

ក្នុងករណីឃាតកម្ម ធ្វើឡើងដោយមានការគិតទុកជាមុន ឬមានការពួនស្ទាក់ ដូច្នេះ ឃាតកម្មនេះមានឈ្មោះថា "ឃាតកម្មដោយគិតទុកជាមុន" ។ បញ្ញត្តិមាត្រា ២០០ ចែងថា ៖

*"ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការ ពួនស្ទាក់។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។*

*ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្ត អំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ឃាតកម្មគិតទុកជាមុន **ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត*** ។

យើងសូមនឹងមិនធ្វើការបកស្រាយលម្អិតទៅលើចំណុច នៃបទឃាតកម្មគិតទុកជាមុននោះទេ ពីព្រោះចំណុចនេះយើងនឹងធ្វើការបកស្រាយនៅក្នុងជំពូកទី២ ដើម្បីបកស្រាយឱ្យបានក្បោះក្បាយ ក្នុងគោលបំណងធ្វើការប្រៀបធៀបជាមួយនឹងបទឃាតកម្ម។

#### ១.៣.២.២. បទឃាតកម្មដោយការប្រើថ្នាំពុល

នៅក្នុងមាត្រាខាងលើនេះក៏ជាស្ថានទម្ងន់ទោសមួយដែរ។ បញ្ញត្តិនៃមាត្រា២០១ បានចែងថា *" ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ** ។ "*

<u>ឧទាហរណ៍</u> ៖ មានបុគ្គលពីរនាក់បានឈ្លោះគ្នាស្រាប់តែម្នាក់បានឃើញថានៅក្បែរហ្នឹង គឺរកអ្វីមិនបានក៏ចាប់បានថ្នាំបាញ់មូសមក រួចក៏កៀកករជនរងគ្រោះជាប់ ហើយយកថ្នាំនោះបាញ់ដាក់ច្រមុះ

ជនរងគ្រោះរហូតដល់ស្លាប់។ នេះគឺជាឃាតកម្មដោយប្រើថ្នាំពុល ពីព្រោះអត់មានបានប្រើមធ្យោបាយអ្វីផ្សេងទៀតទេ គឺយកថ្នាំពុលមកប្រើដើម្បីផ្តាច់ជីវិតជនរងគ្រោះ។

<u>ឧទាហរណ៍</u> ៖ **ក** មានគុំនុំគុំគួនជាមួយ **ខ** រួចក៏ចង់សម្លាប់ ។ **ក** ក៏បានអញ្ជើញ **ខ** ឱ្យទៅញ៉ាំបាយជាមួយខ្លួន។ ពេលទៅដល់គាត់បានរៀបគម្រោងដាក់ថ្នាំពុលនៅក្នុងបាយដើម្បីឱ្យ **ខ** បានហូបបាយនោះទៅហើយត្រូវស្លាប់។

សួរថាតើអំពើនេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ ឬ មាត្រា ២០១ ? គឺតាមមាត្រា ២០០ ពីព្រោះវានៅតែគិតទុកជាមុនដដែល។ កុំច្រឡំថាជាឃាតកម្មដោយការប្រើថ្នាំពុល ដោយភ្លេចគិតទៅដល់ថាមានរៀបចំគម្រោងទុកជាមុនឱ្យសោះ។

ការប្រើថ្នាំពុលនៅទីនេះ គឺចង់បញ្ជាក់ថាយកថ្នាំពុលធ្វើជាមធ្យោបាយក្នុង ការធ្វើឃាតកម្មដែលមិនចូលធាតុផ្សំនៃឃាតកម្មគិតទុកជាមុន គឺអត់មានបានរៀបចំគម្រោងអីមុននោះទេ។ ចំពោះឃាតកម្មដោយប្រើថ្នាំពុលនេះ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬដាក់គុកពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ។

#### ១.៣.២.៣.បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

មាត្រាមួយនេះ គឺជាឃាតកម្មទៅលើជនរងគ្រោះមួយចំនួនដែលច្បាប់កំណត់ថាត្រូវទទួលស្ថានទម្ងន់ទោសនៅក្នុងបញ្ញត្តិមាត្រា ២០២ បានចែងអំពីជនរងគ្រោះទាំងនោះថា ៖

*"ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ** កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ ៖*

*១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។*

*២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។*

*៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។*

*៤-អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។"*

##### ក. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុ

**ចំណុចទី ១** ៖ គឺច្បាប់សំដៅទៅលើបុគ្គលដែលទន់ខ្សោយ តើទន់ខ្សោយដោយសារអ្វីទៅ? គឺទន់ខ្សោយពិសេសដោយសារអាយុ ។

<u>ឧទាហរណ៍</u> ៖ ការធ្វើឃាតកម្មទៅលើមនុស្សដែលក្មេងពេក ហើយខ្វះលទ្ធភាពទប់ទល់ និងការពារខ្លួន ឬក៏អ្នកដែលមានវ័យចាស់ពេក បើមើលទៅវ័យគាត់ទន់ខ្សោយទៅហើយដោយដើរទ្រេតទ្រូតៗ

ពីព្រោះមានអាយុ ៨០-៩០ឆ្នាំទៅហើយ គ្រាន់តែថាក្មេងរត់មកប៉ះក៏ដួលដែរ ទាំងនេះ គឺជាឃាតកម្មទៅលើបុគ្គលដែលទន់ខ្សោយនោះដោយមូលហេតុនៃអាយុ។

<u>ចំណាំ</u> ៖ មិនមែនឱ្យតែអាយុ គឺទន់ខ្សោយទេ អត់យកមូលដ្ឋានអាយុមកមុននោះទេ គេថាបុគ្គលហ្នឹងទន់ខ្សោយពិសេសដោយមូលហេតុអាយុ។

បើមើលទៅលើអាយុគាត់មានស្ថានភាពទន់ខ្សោយទៅហើយនោះ គឺការចោទប្រកាន់ដើម្បីផ្តន្ទាទោសត្រូវធ្វើទៅតាមបញ្ញត្តិមាត្រា ២០២ ចំណុចទី១។ ចំពោះស្ថានភាពអាយុដែលអាចចាត់ទុកជាភាពទន់ខ្សោយពិសេសនោះមានដូចជា ៖

ករណីប្រព្រឹត្តទៅលើក្មេងអាយុ ៤ ទៅ ៥ ឆ្នាំជាដើមនោះ គឺ១០០% ដែលហៅថាទន់ខ្សោយតិចទៅថាក្មេងហ្នឹងឃើញម៉ាប់ៗវាខ្លាំងដែរ អត់មែនខ្សោយទេ គឺមិនមែនអញ្ចឹងឡើយ ពីព្រោះឃាតកម្មទៅលើក្មេងអាយុ ៣ ទៅ ១០ ឆ្នាំចុះមកក្រោមនេះ គឺទន់ខ្សោយហើយ។

បើវាមានអាយុ ១៦-១៧ ឆ្នាំវិញ តើអាចទន់ខ្សោយដែរឬទេ? គឺអាចដែរក្នុងករណីដូចជាមនុស្សដែលខ្វះសារធាតុចិញ្ចឹម ធ្វើឱ្យស្គមស្គាំងតែល្វៃៗដើររញីរញ័រៗ ដូច្នេះមនុស្សប្រភេទនេះហើយ គឺជាមនុស្សដែលទន់ខ្សោយពិសេសនោះ។

### ខ. បុគ្គលដែលជានារីមានគភ៌

**ចំណុចទី ២ ៖** គឺប្រព្រឹត្តទៅលើនារីដែលមានគត៌ ដូច្នេះឃាតកម្មចំពោះនារីមានគត៌ក៏ច្បាប់កំណត់ចូលទៅក្នុងស្ថានទម្ងន់ទោសផងដែរ។ បើសិនជាគត៌នោះមើលឃើញជាក់ស្តែង គឺចូលទៅក្នុងចំណុចនេះហើយ។ ករណីមួយទៀត គឺជនល្មើសដឹងថានាងមានគត៌ ហើយនៅតែធ្វើឃាតកម្មទៅលើនាងទៀត នោះនឹងចូលទៅក្នុងស្ថានទម្ងន់តាមបញ្ញត្តិនៃមាត្រា ២០២ ចំណុចទី ២ នេះដែរ។ នេះគឺយើងនិយាយអំពីឃាតកម្មដោយគ្មានការគិតទុកជាមុនទេ ដែលត្រូវទទួលស្ថានទម្ងន់បែបនេះ។ តែបើសិនជាគិតទុកជាមុន គឺចូលទៅក្នុងមាត្រា ២០០ ទាំងអស់។

**<u>ចំណាំ</u>** ៖ សូមកុំច្រឡំថាប្រព្រឹត្តទៅលើនារីមានគត៌ និងមានការគិតទុកជាមុន បែរជាទៅយកមាត្រា ២០២ មកប្រើវិញ គឺខុសនឹងស្មារតីនៃក្រមនេះហើយ។ ចំពោះបញ្ហានៃការគិតទុកជាមុន ទោះបីជាបុគ្គលប្រភេទហ្នឹងជាមនុស្សទន់ខ្សោយក៏ដោយ ជានារីមានគត៌ក៏ដោយ គឺត្រូវប្រើមាត្រា ២០០ ទាំងអស់ ឱ្យតែមានការគិតទុកជាមុន។ ផ្ទុយទៅវិញប្រសិនបើអត់មានការគិតទុកជាមុនទេ តែប្រព្រឹត្តទៅលើប្រភេទបុគ្គលបែបនេះ គឺត្រូវទទួលស្ថានទម្ងន់តាមបញ្ញត្តិមាត្រា ២០២។

### គ. បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព

**ចំណុចទី ៣ ៖** គឺជាមនុស្សដែលទន់ខ្សោយពិសេស ដោយសារតែមូលហេតុមានជម្ងឺ ឬពិការភាពកាលបើស្ថានភាពបុគ្គលនេះ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។ ចំពោះភាពទន់ខ្សោយពិសេសមិនមែនគ្រាន់តែក្អកផ្តាសាយ ហើយមានឃាតកម្មទៅលើគាត់ គឺចូលក្នុងចំណុចទី៣ នេះទេ ឬគិតថាជាស្ថានភាពទន់ខ្សោយហើយ គឺត្រូវប្រើមាត្រា ២០២ នោះឡើយ។ ក៏ប៉ុន្តែប្រសិនបើគាត់ឈឺធ្ងន់ធ្ងរមែនទែនហើយរហូតដល់ងើបពីគ្រែមិនចង់រួចដើរញើរញ័រៗទៅហើយ នៅពេលដែលមានឃាតកម្មទៅលើបុគ្គលប្រភេទនេះ គឺចូលទៅក្នុងបញ្ញត្តិមាត្រា ២០២ ដែលជាមូលហេតុនៃស្ថានទម្ងន់។ ដូច្នេះយើងត្រូវធ្វើការបែងចែកឱ្យបានច្បាស់ទៅក្នុងស្ថានទម្ងន់ទាំងអស់។ មួយវិញទៀត គឺពិការភាពចំពោះពាក្យថាពិការភាពនេះក៏ត្រូវពិនិត្យទៅតាមស្ថានភាពមួយៗដែរ។ មិនមែនពិការភាពគ្រាន់តែកុតស្លឹកត្រចៀកមួយចំហៀងទេ ពីព្រោះបើនិយាយពីពិការភាព ជនប្រភេទនេះគឺពិការភាពហើយ ប៉ុន្តែមិនមែននោះទេ ស្ថានភាពបែបនេះមិនត្រូវបានចាត់ទុកថាទន់ខ្សោយនោះទេ។ ចុះបើកុតដៃកុតជើង គឺចូលទៅក្នុងចំណុចទី ៣ នេះហើយបើគាត់ពិការដៃម្ខាង និងមិនសូវមានកម្លាំងក៏អាចចូលក្នុងភាពទន់ខ្សោយពិសេសដែរ។ ដោយសារតែគាត់ថមថយកម្លាំងដៃរហើយពីព្រោះមិនដូចអ្នកមានដៃពីរនោះទេ។ ផ្ទុយទៅវិញ បើគាត់ពិការដៃម្ខាងតែគាត់ពូកែវ៉ៃគ្នាយ៉ាងខ្លាំងដូច្នេះក៏អាចឈ្នះគេដែរ។ ដោយមូលហេតុនេះហើយ ទើបគេឱ្យពិចារណាថា តើគាត់ទន់ខ្សោយដោយមូលហេតុពិការភាពដែរ ឬអត់? គេឱ្យយកពាក្យពីរហ្នឹងមកបញ្ចូលគ្នា គឺ**ទន់ខ្សោយពិសេស** និង**ដោយមូលហេតុ** តែចំណុចសំខាន់ជាងគេ គឺពាក្យថា "ទន់ខ្សោយ"។ តើទន់ខ្សោយដោយសារអ្វី? គឺដោយមូលហេតុពិការភាព។ ហេតុនេះបើពិការដៃម្ខាង ប៉ុន្តែគាត់នៅមានកម្លាំងខ្លាំងក្លា ឬរឹងមាំងមានទន់ខ្សោយឯណា! បើមានអ្នកដៃពីរចំនួន៣ នាក់ចូលមកសាកវ៉ៃគ្នាជាមួយគាត់លមើល ម្យ៉ាងទៀតគាត់ គឺជាម្ចាស់ខ្សែក្រវាត់ខ្មៅការ៉ាត់តេដូប៉ុន្មានដាន់ផងកុំឱ្យតែកាំភ្លើង គឺទប់ទល់ជាមួយគាត់មិនបានទេ ដូច្នេះគេត្រូវពិនិត្យមើលផងដែរនៅក្នុងអត្ថន័យនេះ ពីព្រោះធាតុរបស់វាសំខាន់គឺទន់ខ្សោយពិសេសដោយមូលហេតុជម្ងឺ ឬក៏ពិការភាព ហេតុនេះទាល់តែចូលទៅក្នុង ស្ថានភាពហ្នឹង ផ្ទុយទៅវិញបើអត់ទន់ខ្សោយទេ គឺមិនយកចំណុចទី ៣ នៃមាត្រា ២០២ នេះមកប្រើទេ។

ចំពោះមូលហេតុស្រវឹងស្រា ឬញៀនគ្រឿងញៀនមិនចាត់ចូលទៅជាមូលហេតុទន់ខ្សោយពិសេសនោះឡើយ។ ដូច្នេះច្បាប់មិនលើកលែងករណីនេះទេ។

**ឃ. បុគ្គលដែលជាអ្នករាជការសាធារណ:**

**ចំណុចទី ៤ ៖** គឺប្រព្រឹត្តទៅលើអ្នករាជការសាធារណ: នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ តើអ្នកណា គឺជាអ្នករាជការសាធារណ:? អត្ថន័យលម្អិតគឺមាននៅក្នុងបញ្ញត្តិមាត្រា ៣០ នៃក្រមនេះបានឱ្យអត្ថន័យនៃអ្នករាជការសាធារណ:ច្បាស់ណាស់

និងរួមបញ្ចូលទាំងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតផងដែរ ទាំងអស់នេះ គឺសុទ្ធតែជាអ្នករាជការសាធារណៈទាំងអស់។ ដូច្នេះដើម្បីងាយស្រួលក្នុងការសិក្សានោះ យើងសូមលើកយកមាត្រា ៣០ មកបង្ហាញទាំងស្រុងតែម្តង៖

***១-អ្នករាជការសាធារណៈមានន័យថា ៖***

*ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុ របស់បុគ្គល នោះឡើយ ។*

*ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។*

***២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ៖***

*ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំង ពលរដ្ឋ ដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។*

សរុបមកប្រសិនបើជាប្រព្រឹត្តអំពើឃាតកម្មទៅលើអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងាររបស់គាត់ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់គាត់ គឺត្រូវទទួលនូវស្ថានទម្ងន់ទោសតាមចំណុចទី៤ នៃមាត្រាខាងលើ (មាត្រា ២០២) ។ នៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារ និងនៅក្នុងឱកាសនៃការបំពេញមុខងារ គឺខុសគ្នាត្រង់៖

ចំពោះពាក្យថា ***នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន*** គឺសំដៅទៅលើអ្នកហ្នឹងមានមុខងារហ្នឹង ហើយទៅធ្វើកិច្ចការ គឺជាកិច្ចការរបស់គាត់ហ្នឹង។

<u>ឧទាហរណ៍</u> ៖ ខាងមន្ត្រីនគរបាលយុត្តិធម៌ ចុះទៅធ្វើការត្រួតពិនិត្យបទល្មើស ស្រាប់តែនៅពេលដែលឃើញជនល្មើស គាត់ក៏ដេញតាមជននោះនៅខណៈនោះជនល្មើសបានប្រព្រឹត្តអំពើឃាតកម្មមកលើមន្ត្រីនគរបាលយុត្តិធម៌នេះ គឺគេហៅថា "អំពើឃាតកម្មលើអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ"។

ចំណែកឯ ***នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន*** គឺគាត់អត់មានមុខងារនៅខាងហ្នឹងនោះទេក៏ប៉ុន្តែគាត់ទៅសហការជួយគេ។ ដូច្នេះអ្នកដែលទៅចូលរួមសហការជួយគេ ហើយគាត់គឺជាអ្នករាជការដែរ តែគាត់មានមុខងារគ្រាន់តែទៅចូលរួមសហការជួយគេ ដោយមិនមែនស្ថិតនៅ

ក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់បែបនេះ គឺគេហៅថាអ្នករាជការសាធារណៈនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

ឧទាហរណ៍ ៖ ដូចជាមន្ត្រីផ្សេងទៀតដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ហើយគាត់ទៅជួយសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ នៅពេលដែលមានអំពើឃាតកម្មមកលើគាត់ គឺគេហៅថា "អំពើឃាតកម្មលើអ្នករាជការសាធារណៈនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន"។ អញ្ចឹងឃាតកម្មទៅលើអ្នករាជការសាធារណៈនេះ ទោះបីជានៅក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារ ក៏ដោយ ឬនៅក្នុងឱកាសនៃការបំពេញមុខងារក៏ដោយ គឺត្រូវទទួលនូវស្ថានទម្ងន់ទោសទៅតាមចំណុចទី ៤ នៃមាត្រា ២០២ ក្រមព្រហ្មទណ្ឌ។

### ១.៣.២.៤. បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ

*"ឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ** កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ ៖*

*១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬសុំឱ្យធ្វើការជួសជុលព្យសនកម្ម ។*

*២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។*

*៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលព្យសនកម្ម ។*

*៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។*[4]

នៅក្នុងឃាតកម្មដោយសារគោលដៅនេះ គឺគោលដៅរបស់ជនល្មើសចង់ធ្វើឃាតកម្មទៅលើបុគ្គលមួយចំនួនដូចខាងលើនេះដើម្បីបញ្ចៀសនូវការស្វែងរកយុត្តិធម៌។

#### ក. ករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនទាន់ប្តឹង

**ចំណុចទី ១** ៖ គឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យគាត់ទៅប្តឹងបរិហារពីបទល្មើស ឬកុំឱ្យទៅសុំធ្វើការជួសជុលព្យសនកម្ម។

ឧទាហរណ៍ ៖ មានបទល្មើសណាមួយកើតឡើង ជនល្មើសគិតថាធ្វើយ៉ាងម៉េចកុំឱ្យជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនេះ ទៅប្តឹងបរិហារគាត់បាន ក៏ទៅសម្លាប់ផ្តាច់ជីវិតជនរងគ្រោះ ឬដើមបណ្តឹង

[4] មាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

រដ្ឋប្បវេណីដើម្បីបំបិទដានតែម្តង ក្នុងគោលបំណងកុំឱ្យមានអ្នកដឹងច្រើនពេក ពីព្រោះបើគាត់នៅរស់ប្រាកដជាទៅប្តឹងហើយ អញ្ចឹងក៏ធ្វើឃាតកម្មទៅលើគាត់។ នេះគឺជាឃាតកម្មដោយមានគោលដៅ ដូច្នេះត្រូវទទួលស្ពានទម្ងន់ទោសតាមបញ្ញត្តិមាត្រា ២០៣។

**ខ. ករណីសាក្សី មិនទាន់ផ្តល់សក្ខីកម្ម**

**ចំណុចទី ២** ៖ ឃាតកម្មទៅលើសាក្សី គឺដើម្បីបញ្ចៀសកុំឱ្យរកយុត្តិធមិបាន គាត់ក៏ទៅធ្វើឃាតកម្មលើសាក្សី។ នេះគឺជាករណីអត់មានគម្រោងទេ តែប្រសិនបើមានគម្រោងគិតទុកជាមុន គឺចូលទៅក្នុងមាត្រា ២០០។ បញ្ហានេះ គឺដោយសារតែគាត់ខឹងថាអ្នកដែលជា សាក្សីនោះបានដឹងរឿងច្បាស់ ម្ល៉េះហើយភ្លាមៗហ្នឹងគាត់ក៏បានប្រើពាក្យគម្រាមកំហែងចំពោះសាក្សីដើម្បីធ្វើឱ្យសាក្សីខ្លាចពុំហ៊ានផ្តល់ចម្លើយ។ ប៉ុន្តែសាក្សីមិនព្រម ពេលនោះជនល្មើសក៏សម្លាប់សាក្សី ចោលតែម្តងទៅ ដែលទង្វើនេះ គឺសម្លាប់ផ្តាច់ជីវិតដើម្បីកុំឱ្យសាក្សីទៅផ្តល់សក្ខីកម្មជូនដល់ស្ថាប័នមានសមត្ថកិច្ច។ នេះគឺជាឃាតកម្មដោយសារមានគោលដៅត្រូវមានស្ពានទម្ងន់។

**គ. ករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងរួចហើយ**

**ចំណុចទី ៣** ៖ គឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យជួសជុលព្យាសនកម្មមានន័យថា គឺដោយសារតែជននោះទៅប្តឹងរួចហើយ។ ជនល្មើសអត់មានគម្រោងគិតទុកជាមុនទេ ប៉ុន្តែដោយសារតែជនរងគ្រោះបានដាក់ពាក្យបណ្តឹងរួចទៅហើយ និងមិនអាចធ្វើការសម្រុះសម្រួលគ្នាបានស្រាប់តែជនល្មើសខឹងសម្បារយ៉ាងខ្លាំងក៏ដាក់ថ្នូសស្លាប់បាត់ទៅ។ នេះគឺឃាតកម្មទៅលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្តឹងរួចហើយ។

**ឃ. ករណីសាក្សី បានផ្តល់សក្ខីកម្មរួចហើយ**

**ចំណុចទី ៤** ៖ ឃាតកម្មទៅលើសាក្សី ដោយសារសាក្សីបានទៅផ្តល់សក្ខីកម្មរួចហើយ នៅមុខស្ថាប័នមានសមត្ថកិច្ចណាមួយដូចជានៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ឬក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដំណាក់កាលនៃការជំនុំជម្រះ ឬក៏នៅក្នុងដំណាក់កាលនៃនីតិវិធីបណ្តឹងផ្សេងទៀត ស្រាប់តែជនល្មើសបានសម្លាប់សាក្សីនោះចោលនេះ គឺជាស្ពានទម្ងន់ទោសដែរសម្រាប់មាត្រា ២០៣ ប្រសិនបើគ្មានការគិតទុកជាមុនដូចមាត្រា ២០០។

<u>**ចំណាំ**</u> ៖ ចំណុចទី១ និងចំណុចទី៣ គឺឃាតកម្មលើជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដូចតែគ្នាទេ។ គ្រាន់តែខុសគ្នានៅត្រង់ថា ចំណុចទី១ គឺជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី អត់ទាន់បានទៅប្តឹងទេ ឯចំណុចទី៣ គឺបានទៅប្តឹងរួចហើយ។ ចំណែកចំណុចទី២ និងចំណុចទី៤ គឺទៅលើសាក្សីដូចគ្នា។ គ្រាន់តែខុសគ្នាត្រង់ចំណុចទី២ គឺសាក្សីអត់ទាន់បានទៅឆ្លើយ ឬទៅផ្តល់សក្ខីកម្មនោះទេ

ចំណែកឯចំណុចទី៤ គឺសាក្សីបានទៅផ្តល់ភស្តុតាងជូនតុលាការរួចហើយ ឬទៅផ្តល់ភស្តុតាងនៅចំពោះនីតិវិធីនៃបណ្តឹងណារួចហើយ ក្រោយមកជនល្មើសក៏បានធ្វើឃាតកម្មទៅលើជននេះ។ ខ្ញុំសូមបញ្ជាក់ឡើងវិញថានៅក្នុងករណីដែល អត់មានការគិតទុកជាមុន ដូច្នេះត្រូវផ្តន្ទាទោសពី ***១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ*** នេះបើយោងទៅតាមបញ្ញត្តិមាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌ ។

**១.៣.២.៥.បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ**

*" ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ** កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។[5] "*

យោងតាមការបកស្រាយខាងលើ យើងបានឃើញឃាតកម្មទៅលើអ្នករាជការសាធារណៈនៅក្នុងមាត្រា២០២ ចំណុចទី៤។ រីឯមាត្រា២០៤នេះ គឺជនល្មើសជាអ្នករាជការសាធារណៈវិញម្តងដែលនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់ ឬក្នុងឱកាសនៃការបំពេញមុខងាររបស់គាត់ ហើយគាត់បានទៅធ្វើឃាតកម្មលើរូបគេ។

**ក. ប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន**

មានដូចជាមន្ត្រីមួយដែលចុះទៅប្រតិបត្តិច្បាប់ ដោយសារតែក្នុងឱកាសនៃការបំពេញមុខងារនេះ ឬក៏ក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់នេះ គាត់បានទៅសម្លាប់ជនណាម្នាក់ ដោយមិនមែនចូលទៅក្នុងស្ថានភាពនៃការការពារស្របច្បាប់នោះទេ។ ប៉ុន្តែដោយសារតែគាត់ខឹងសម្បារនឹងជនល្មើសខ្លាំងពេក ដូចជាមន្ត្រីនគរបាលយុត្តិធម៌ទៅដេញចាប់ជនល្មើស ពេលចាប់បានហើយជនល្មើសហាក់បីដូចជាតវ៉ាខ្លាំងពេក។ មន្ត្រីនោះក៏ថាយើងខំដេញឯងហត់សឹងស្លាប់ ហេតុអីឯងតវ៉ាច្រើនម៉្លេះ? បន្ទាប់មកក៏សម្លាប់ជនល្មើសចោលតែម្តងទៅ បែបនេះ គឺគេហៅថា ឃាតកម្មដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន។

**ខ. ប្រព្រឹត្តនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន**

ផ្សេងពីនេះទៅទៀត ប្រសិនបើមន្ត្រីរាជការដែលទៅជួយសហការបំពេញការងារចាប់ជនល្មើសដោយមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួនទេ តែបែរជាទៅសម្លាប់ជនល្មើសនោះ។ ហេតុដូច្នេះ គឺជាឃាតកម្ម ដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។ ឃាតកម្មប្រភេទនេះត្រូវទទួលស្ថានទម្ងន់ទោសតាមបញ្ញត្តិមាត្រា ២០៤ គឺត្រូវជាប់គុកចន្លោះពី ***១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។***

[5] មាត្រា ២០៤ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

### ១.៣.២.៦. បទឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

*"ឃាតកម្មដែលកើតក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ **ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត** [6]"*

**ក. ឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោរឃៅ**

មានន័យថា នៅពេលធ្វើទារុណកម្មទៅក៏សម្លាប់ជនរងគ្រោះតែម្តង ឬមួយក៏ក្រោយពេលដែលធ្វើទារុណកម្មហើយក៏សម្លាប់ចោលទៅ។ ទាំងនេះគឺជាឃាតកម្មនៅក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ។ ករណីនេះត្រូវទទួលស្ថានទម្ងន់ទោសតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ គឺត្រូវដាក់គុកអស់មួយជីវិត។

**ខ. ឃាតកម្មដោយមានអំពើរំលោភសេពសន្ថវៈ**

ពេលរំលោភសេពសន្ថវៈរួច ក៏សម្លាប់ជនរងគ្រោះតែម្តង ឬមួយក៏ក្រោយពេលរំលោភហើយក៏សម្លាប់ជនរងគ្រោះចោលតែម្តងទៅ ទាំងនេះ គឺជាឃាតកម្មនៅក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ ករណីនេះក៏ត្រូវទទួលស្ថានទម្ងន់ទោស តាមបទប្បញ្ញត្តិនៃមាត្រា ២០៥ ដែរ គឺត្រូវដាក់គុកអស់មួយជីវិតដូចគ្នា។

**<u>គួរកត់សម្គាល់</u>** ៖ ប្រហែលជាពេលខ្លះយើងភ្លេចគិតមើលមាត្រា ២០៥។ នៅពេលដែលមានអំពើរំលោភហើយសម្លាប់ ប្រហែលជាខំទៅបើកមើលពីមាត្រា ២៣៩ ដល់មាត្រា ២៤៥ ហើយមើលទៅដោយគិតថារឿងនេះ គឺរំលោភហើយសម្លាប់ទៀត ដូច្នេះបើមិនបានមកគិតដល់មាត្រា ២០៥ ទេ យើងហ៊ានទៅចោទពីរមាត្រា គឺខុសស្រឡះតែម្តង ពីព្រោះទោសជាប់គុកវា គឺស្រាលណាស់ ឬខុសគ្នាឆ្ងាយណាស់។ ប្រសិនជាចោទពីបទឃាតកម្មមួយ និងចោទពីបទរំលោភសេពសន្ថវៈមួយទៀតនៅក្នុងអំពើនេះ គឺផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងច្រើនបំផុតបាន ១៥ ឆ្នាំទេ លើកលែងតែយើងរកភស្តុតាងបញ្ជាក់ថាឃាតកម្មនេះបានគិតទុកជាមុន។ ប៉ុន្តែចំពោះអំពើនេះ គឺសូមចងចាំថាមាត្រា ២០៥ បានចែងច្បាស់ហើយទោះបីជាគ្មានការគិតទុកជាមុនក៏ដោយឱ្យតែរំលោភហើយសម្លាប់ ឬក៏ក្នុងពេលរំលោភហ្នឹង ដោយសារតែជនរងគ្រោះប្រតាយប្រតប់ខ្លាំងពេកជនល្មើសក៏ច្របាច់កជនរងគ្រោះឱ្យស្លាប់បាត់បង់ជីវិតទៅ។ នេះគឺជាឃាតកម្មក្នុងពេលរំលោភសេពសន្ថវៈ ឬឃាតកម្មនៅក្រោយពេលរំលោភសេពសន្ថវៈបែបនេះត្រូវផ្តន្ទាទោសអស់មួយជីវិតតាមបញ្ញត្តិមាត្រា ២០៥ ។

[6] មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

ដូច្នេះសូមកុំច្រឡំទៅចោទចំនួនពីរបទល្មើស គឺសម្លាប់ផង និងរំលោភផង ពីព្រោះបទឃាតកម្មតាមបញ្ញត្តិមាត្រា ១៩៩ បើអត់មានស្ថានទម្ងន់ទោសទេ គឺជាប់គុកបានតែចន្លោះពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំប៉ុណ្ណោះ និងរំលោភសេពសន្ថវៈតាមបញ្ញត្តិមាត្រា ២៣៩ បើអត់មានស្ថានទម្ងន់ទោសទេ គឺអាចដាក់គុកបានតែចន្លោះពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំទេ។ ហេតុនេះបទល្មើសចំនួនពីរនៅក្នុងអំពើដែលយើងចោទនេះ តុលាការមិនអាចប្រកាសទោសលើសពី ១៥ ឆ្នាំទេ ពីព្រោះមាត្រា ២៣៩ គឺអតិបរមានៃទោសរបស់វាស្មើ១០ ឆ្នាំ និងមួយទៀតត្រង់មាត្រា ១៩៩ គឺអតិបរមានៃទោសរបស់វាស្មើ ១៥ ឆ្នាំ ។ បើដូច្នេះមែន តុលាការអត់មែនទៅផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ១០ ឆ្នាំ និងបទឃាតកម្ម ១៥ ឆ្នាំ បើយើងបូកទៅស្មើ ២៥ ឆ្នាំ គឺខុសទៅនឹងគោលការណ៍ក្នុងបញ្ញត្តិមាត្រា ១៣៧ "ការចោទប្រកាន់តែមួយ" នៃក្រមព្រហ្មទណ្ឌ។ ហេតុនេះ គឺមិនអាចទៅយកបទល្មើសដែលយើងចោទចំពោះជននោះច្រើន បែរជាយើងទៅផ្តន្ទាទោសម្តងមួយៗ រួចសរុបចេញចំនួនទោសទាំងអស់ដូចនៅប្រទេសអាមេរិកនោះទេ។

## ១.៤-ទោសបន្ថែមនៃបទឃាតកម្ម ៖ ប្រភេទ និងរយៈពេល

ក្រៅពីមូលទោសដែលមានកំណត់នៅក្នុងប្បញ្ញត្តិនីមួយៗ ទៅតាមស្ថានទម្ងន់របស់វា គឺថាសម្រាប់បទឃាតកម្មនេះក៏មាន "ទោសបន្ថែម" ដូចមានចែងនៅក្នុងមាត្រា ២០៦ គឺ ៖

**មាត្រា ២០៦.- ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល**

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះមានទោសបន្ថែមដូចតទៅនេះ ដែលអាចត្រូវបានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ចំពោះគោលការណ៍នៃទោសបន្ថែមនេះ គឺទាល់តែមានចែងជាក់លាក់នៅក្នុងច្បាប់ ដូចជាករណីដែលមានចែងនៅក្នុងមាត្រា ២០៦ អញ្ចឹង។ ផ្ទុយទៅវិញ ប្រសិនបើគ្មានចែងជាក់លាក់នៅក្នុងច្បាប់បែបនេះទេ តុលាការមិនអាចនឹកឃើញទៅប្រកាសទោសបន្ថែម ដើម្បីបន្ថែមទៅលើមូលទោស (ទោសដាក់ពន្ធនាគារ និងទោសពិន័យ) បាននោះទេ។ ពីព្រោះថាក្រៅពីប្រកាសមូលទោសប្រសិនជាតុលាការពិនិត្យឃើញថាច្បាប់មានចែងអំពីទោសបន្ថែម តុលាការអាចប្រកាសទោសបន្ថែមដើម្បីបន្ថែមទៅលើមូលទោសក៏បាន ឬមួយមិនប្រកាសក៏បានដែរ លើកលែងតែច្បាប់បានចែងកំណត់ជាកាតព្វកិច្ចឱ្យប្រកាសជាដាច់ខាតជាគម្រូ គឺប្រើភាគច្រើនចំពោះនីតិបុគ្គល។ ក៏ប៉ុន្តែមាត្រា ២០៦ នេះគេប្រើថា "អាចត្រូវបានប្រកាស" ទេ តែគឺអត់មានន័យថា "ត្រូវតែប្រកាស" នោះឡើយ ។ ដូចនេះតុលាការអាចប្រកាសបន្ថែមទៅលើមូលទោសទៀតក៏បានដែរ។

ឥឡូវយើងសូមបញ្ចប់ការបកស្រាយជំពូកទី១ ត្រង់កន្លែងនេះ ហើយបន្តទៅខាងមុខ នឹងធ្វើការបកស្រាយពី "បទឃាតកម្មគិតទុកជាមុន" ក្នុងជំពូកទី២ ដូចតទៅ៖

# ជំពូកទី ២
# បទឃាតកម្មគិតទុកជាមុន

ក្នុងករណីឃាតកម្ម ធ្វើឡើងដោយមានការគិតទុកជាមុន ឬមានការពួនស្ទាក់ ដូច្នេះឃាតកម្មនេះមានឈ្មោះថា "ឃាតកម្មដោយគិតទុកជាមុន" ។ បញ្ញត្តិមាត្រា ២០០ ចែងថា ៖

## ២.១. និយមន័យនៃបទល្មើសឃាតកម្មគិតទុកជាមុន

នៅក្នុងការបកស្រាយ ដែលទាក់ទងទៅនឹងនិយមន័យនៃបទល្មើសឃាតកម្មគិតទុកជាមុន ត្រូវបានបង្ហាញដោយលើកឡើងនូវការចែងនៅក្នុងច្បាប់ពីរ គឺច្បាប់ព្រហ្មទណ្ឌអន្តរកាល និង ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

### ២.១.១. ច្បាប់ព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩២

ជនណាដែលសំលាប់ ឬប៉ុងប៉ងសំលាប់ជនម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវ បទឧក្រិដ្ឋរបស់ខ្លួន ឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសំលាប់ ឬប៉ុនប៉ងសំលាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋមនុស្សឃាដគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ។

ការគិតទុកជាមុន គឺគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើបុគ្គលណាមួយ[7]។
ការពួនស្ទាក់ គឺជាការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ។

### ២.១.២. ក្រមព្រហ្មទណ្ឌ២០០៩

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការ ពួនស្ទាក់ ។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។ ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត [8]។

## ២.២. ធាតុផ្សំនៃបទល្មើស

ធាតុផ្សំនៃបទល្មើសចំពោះបទឃាតកម្មគិតទុកជាមុននេះ ត្រូវបានលើកយកមកធ្វើការបកស្រាយនូវធាតុផ្សំទាំងបីដូចជា៖ ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ និងធាតុអត្តនោម័ត។

[7] មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌសម័យអន្តរកាលឆ្នាំ ១៩៩២
[8] មាត្រា ២០០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩

**២.១.១. ធាតុផ្សំនីត្យានុកូល**

ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់នេះ យើងសូមលើកយកការចែងនៅក្នុងច្បាប់ចាស់(ច្បាប់ព្រហ្មទណ្ឌអន្តរកាល) និងច្បាប់ថ្មី(ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩)ដូចខាងក្រោម៖

**២.២.១.១. ច្បាប់ចាស់**

មនុស្សឃាតគិតទុកជាមុន គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានត្រូវបានផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរផងដែរនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ បទល្មើសនេះមានចែងក្នុងមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០២។ មាត្រា ៣ នៃច្បាប់នេះចែងថា "ជនណាដែលសំលាប់ ឬប៉ុងប៉ងសំលាប់ជនម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសំលាប់ ឬប៉ុងប៉ងសំលាប់ជនណាម្នាក់ទៀតក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬការរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនារគារតម្រូវអោយធ្វើការពី ១៥ ឆ្នាំ ទៅ ២០ ឆ្នាំ ឬ អស់មួយជីវិត"។

**២.២.១.២. ច្បាប់ថ្មី**

តាមមាត្រា២០០ កថាខណ្ឌទី៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ កំណត់ទោសនៃអំពើឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ដែលក្រមព្រហ្មថ្មីនេះមានទម្ងន់ទោសធ្ងន់ជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយកំណត់ក្នុងមាត្រា៣១ ដាក់ពន្ធនាគារត្រឹមតែ១០ ទៅ ២០ឆ្នាំ។

ក្រមព្រហ្មទណ្ឌថ្មី បានកំណត់ទោសបន្ថែមបូកពីលើទោសដាក់ពន្ធនាគារ ដោយមានកំណត់ក្នុងមាត្រា ២០៦។

**២.២.២. ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈនៃបទល្មើស**

នៅក្នុងចំណុចនេះ យើងលើកយកនូវច្បាប់ចំនួនពីរដែលបកស្រាយពីធាតុសន្យានុម័តគឺច្បាប់ចាស់ និងច្បាប់ថ្មី ហើយនៅក្នុងផ្នែកនេះ យើងក៏លើកឡើងនូវចំណុចមួយទៀត គឺបទប្បញ្ញត្តិដែលចែងពីរូបភាពនៃឃាតកម្មគិតទុកជាមុន ដែលបង្ហាញពីបទល្មើសមួយចំនួនដែលមានលក្ខណៈដូចបទឃាតកម្មគិតទុកជាមុន។

**២.២.២.១. ច្បាប់ចាស់**

ធាតុសម្ភារៈនៃបទល្មើសមនុស្សឃាតគិតទុកជាមុន គឺជាលក្ខណៈដូចគ្នានឹងអំពើសំភារៈនៃបទល្មើសមនុស្សឃាតដោយចេតនា។ ប៉ុន្តែអ្វីដែលធ្វើការបែងចែករវាងបទល្មើសទាំងពីរនេះ គឺស្ថានទម្ងន់ទោសដែលមាននៅក្នុងបទល្មើសមនុស្សឃាតគិតទុកជាមុន។ យោងតាមមត្រា ៣ នៃ

ច្បាប់ស្តីពីស្ថានទម្ងន់ទោសខាងលើ ស្ថានទម្ងន់ទោសនៅក្នុងអំពើមនុស្សឃាតគិតទុកជាមុនមានដូចជា៖

- ការគិតទុកជាមុន
- ការពួនស្ទាក់
- ការប្រព្រឹត្តក្នុងពេលចោរកម្ម ឬរំលោភសេពសន្ថវៈ

**ក. ការគិតទុកជាមុន**

យោងតាមមាត្រា ៣ វាក្យខណ្ឌ ២ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសខាងលើ ការគិតទុកជាមុនត្រូវបានគេអោយនិយមន័យថា គឺជា "គំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើបុគ្គលណាម្នាក់"។ យោងតាមនិយមន័យនេះ គំរោងទុច្ចរិតក្នុងការធ្វើឃាតកម្មទៅលើជនរងគ្រោះ ដាច់ខាតត្រូវកើតមានមុនពេលឃាតកម្ម។ ពាក្យថាគំរោងនេះ គឺសំដៅទៅលើការរៀបចំគិតទុកជាមុន ដោយមានការគិតគូរពីចារីនៃបទល្មើស ពុំមែនជាការសំរេចចិត្តភ្លាម ហើយប្រព្រឹត្តអំពើល្មើសក្នុងពេលជាមួយគ្នានោះទេ។ និយាយជារួម គឺត្រូវមានចន្លោះពេលមួយរវាងការសំរេចចិត្តលើគំរោងប្រព្រឹត្តបទល្មើស និងការអនុវត្តន៍គំរោងនោះដោយចារី។

ឧទាហរណ៍៖ លោក "ក" បានទិញកាំភ្លើងទុកសំលាប់ "ខ" ដែលជាសត្រូវរបស់ខ្លួន ហើយនៅថ្ងៃមួយលោក "ក" ក៏បានយកកាំភ្លើងនោះទៅសំលាប់ "ខ" តែម្តង។ នេះជាការគិតទុកជាមុនរបស់លោក "ក" ហើយដែលនេះជាបទល្មើសមនុស្សឃាតដោយមានការគិតជាមុន។

**ខ.ការពួនស្ទាក់**

យោងតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសខាងលើ ការពួនស្ទាក់ត្រូវបានគេអោយនិយមន័យថា គឺជាការឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយ ដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ។ ជាធម្មតាការពួនស្ទាក់នេះ គឺជាការបង្កប់ការគិតទុកជាមុនជាដរាប ប៉ុន្តែការគិតទុកជាមុនវិញ អាចកើតមានដោយមិនមានការពួនស្ទាក់បាន។

**គ.អំពើចោរកម្ម ឬអំពើរំលោភសេពសន្ថវៈ**

យោងតាមមាត្រា ៣ វាក្យខណ្ឌ ១ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ បានចាត់ទុកអំពើមនុស្សឃាតដោយចេតនា ជាអំពើមនុស្សឃាតគិតទុកជាមុន នៅពេលដែលអំពើមនុស្សឃាតដោយចេតនានោះ កើតមានក្នុងពេលដែលចារីប្រព្រឹត្តចោរកម្ម ឬអំពើរំលោភសេពសន្ថវៈ។ ដូចនេះអំពើល្មើស(ចោរកម្ម ឬរំលោភសេពសន្ថវៈ) ដែលកើតមានក្នុងកាលៈទេសៈដែលបានរៀបរាប់ខាងលើនេះ គឺជាស្ថានទម្ងន់មួយដែលធ្វើអំពើមនុស្សឃាតដោយចេតនា ក្លាយទៅជាអំពើមនុស្សឃាតគិតទុកជាមុន។

ឧទាហរណ៍: ជនល្មើសបានរៀបចំគំរោងក្នុងការប្រព្រឹត្តអំពើប្លន់ ដោយពួកគេបានទិញកាំភ្លើងទុកមុនពេលធ្វើសកម្មភាព។ ក្នុងពេលធ្វើសកម្មភាពប្លន់ ដោយខ្លាចបែកការណ៍ ព្រោះជនរងគ្រោះបានស្គាល់មុខ និងឈ្មោះរបស់គេ ជនល្មើសក៏បានសំលាប់ជនរងគ្រោះដើម្បីបំបិទមាត់ អំពើដែលគេបានប្រព្រឹត្តនេះ ត្រូវបានគេចាត់ទុកថា វាជាបទល្មើសមនុស្សឃាតគិតទុកជាមុន។

**២.២.២.១. ច្បាប់ថ្មី**

ចំពោះការបកស្រាយ ទៅលើធាតុផ្សំសត្យានុម័តនៃបទល្មើសឃាតកម្មគិតទុកជាមុន យើងសូមលើកយកនូវចំណុចពីរសំខាន់ៗមកធ្វើការបង្ហាញ គឺការគិតទុកជាមុន និងការពួនស្ទាក់ ។

**ក. ការគិតទុកជាមុន**

"**ការគិតទុកជាមុន**" នេះយើងនឹងលើកឧទាហរណ៍មកវិភាគទាំងអស់គ្នាថាតើ គឺជាអំពើឃាតកម្មគិតទុកជាមុន ឬក៏មិនមែននោះ?

ឧទាហរណ៍១ ៖ នៅក្នុងស្ថានភាពបច្ចុប្បន្ន អ្នកខ្លះមានគ្រោះថ្នាក់ចរាចរណ៍បន្តិចបន្តួច ពេលចុះពីលើឡានមក មិនជួយដោះស្រាយតាមផ្លូវច្បាប់ បែរទៅជាជជែកយកឈ្នះរៀងខ្លួន ក៏ប៉ះសំដីនិងគ្នារួចវាយគ្នារហូតដល់មានម្នាក់ស្លាប់។

ឧទាហរណ៍២ ៖ នៅក្នុងករណីមួយទៀត គឺស្រដៀងគ្នាដែរ ពីព្រោះ **ក** និង **ខ** មានគ្រោះថ្នាក់ចរាចរណ៍ រួចឈ្លោះគ្នាតឹងសរសៃរក ហើយចង្អុលមុខគ្នាមួយសន្ទុះ ពួកគាត់ក៏ដើរចេញទៅបើកឡានរៀងៗខ្លួនបាត់ទៅ ។ លុះក្រោយមក **ក** គិតថាតាំងពីកើតមកមិនដែលឃើញ អ្នកណាព្រហើនដូចអាមួយហ្នឹងទេ ហ៊ានមកចង្អុលមុខឯង យើងគិតថាលែងចង់ឱ្យឃើញ មុខវាតទៅទៀតនៅលើផែនដីនេះហើយ ទុកឱ្យរស់នៅក្នុងលោកទៀតមិនកើតទេ ។ គ្រាន់តែ ជិះឡានបានប្រហែលជា ៤ ទៅ ៥ រយម៉ែត្រ ក៏បត់ឡានតាមទៅរក **ខ** វិញ ដល់ពេលឃើញ **ខ** ក៏ទាញកាំភ្លើងបាញ់ផ្ទងៗរហូតដល់ស្លាប់ ។

សំណួរ ៖ តើឧទាហរណ៍ទី ១ និង ទី ២ មួយណា គឺជាឃាតកម្មគិតទុកជាមុន?

ចម្លើយ ៖ ភាពត្រឹមត្រូវ គឺឧទារហាណ៍ទី២ ពីព្រោះថាជាឃាតកម្មគិតទុកជាមុនដោយសារតែមានគម្រោង បើទោះបីជាគម្រោងគិតរៀបចំនៅក្នុងការធ្វើអំពើឃាតកម្មនេះរយៈពេលខ្លី ឬក៏រយៈពេលវែងប៉ុនណាក៏ដោយ។ មិនមែនមានន័យថា ទាល់តែមានរៀបចំនូវប្លង់សកម្មភាព ដូចយើងធ្វើគម្រោងការងារនៅតាមស្ថាប័នអីនោះទេ គឺអត់ចាំបាច់ដល់ប៉ុណ្ណឹងទេ គឺឱ្យតែគម្រោងគិតក្នុងចិត្តដើម្បីធ្វើយ៉ាងណាទៅសម្លាប់ជនរងគ្រោះទៅផ្តាច់យកជីវិតជនរងគ្រោះ ទោះបីជារយៈពេលនៃការគិតទុកនេះមានរយៈពេលវែង ឬខ្លីប៉ុនណាក៏ដោយ។

**ខ. ការពួនស្ទាក់**

ករណីមួយទៀតគឺ **"ការពួនស្ទាក់"** មានន័យថា ទៅឃ្លាំចាំមើលជនរងគ្រោះនៅកន្លែងណាមួយក្នុងគោលដៅផ្តាច់ជីវិតជនរងគ្រោះ។ បើកាលណាមានការឃ្លាំចាំដើម្បីទៅផ្តាច់ជីវិតជនរងគ្រោះបែបនេះ អំពើដែលធ្វើឡើងទៅលើជនរងគ្រោះនោះ គេហៅថា "ឃាតកម្មគិតទុកជាមុន" ទោះបីជាមានការភ័ន្តច្រឡំទៅលើជនរងគ្រោះក៏ដោយ។

<u>ឧទាហរណ៍</u> ៖ រង់ចាំដើម្បីសម្លាប់ **ខ** ហើយដឹងថា **ខ** ជារៀងរាល់ថ្ងៃដល់ម៉ោងប៉ុណ្ណឹង គឺដឹងថាដើរមកតាមផ្លូវហ្នឹងហើយ រួចខ្លួនក៏ទៅរង់ចាំនៅផ្លូវហ្នឹងដែរទៅស្រាប់តែ **ខ** មកដល់ **ក** បានឃើញក៏ដកកាំភ្លើងបាញ់ ខ រហូតដល់ស្លាប់បាត់ទៅនេះ គឺជាឃាតកម្មគិតទុកជាមុន។ ចុះបើថៃ្ងជន្យអីនៅថ្ងៃហ្នឹងស្រាប់តែមានអ្នកដែលស្លៀកពាក់សំលៀកបំពាក់ និងរាងរ៉ូវ គឺវាស្រដៀងនឹង **ខ** ដែរតែ **ខ** អត់បានមកទេ គ្រាន់តែអ្នកផ្សេងដែលស្រដៀងហ្នឹងគាត់ដើរមកតាមផ្លូវហ្នឹងដែរ ស្រាប់តែ **ខ** ក៏បាញ់យកតែម្តងដោយគ្មានបានចាំមើលមុខ **ខ** ឬមិន **ខ** ទេ ដោយគិតថាអាហ្នឹងហើយ សម្បុរហ្នឹងហើយ ខោអាវហ្នឹងហើយ ក៏បាញ់ផ្ទងៗស្លាប់ទៅ។ សំណួរ ៖ សួរថាតើនេះ គឺជាអំពើឃាតកម្មគិតទុកជាមុនដែរឬទេ?

ចម្លើយ ៖ នេះគឺនៅតែជាឃាតកម្មគិតទុកជាមុនដដែល ទោះបីជាគោលដៅជនរងគ្រោះនេះច្រឡំក៏ដោយ ពីព្រោះមានការពួនស្ទាក់ជនរងគ្រោះ រងចាំជនរងគ្រោះ ប៉ុន្តែភ័ន្តច្រឡំ។ ការភ័ន្តច្រឡំបែបនេះ គឺគាត់បានគិតថាជនហ្នឹងជាជនរងគ្រោះរួចហើយ ដូច្នេះនៅតែជាឃាតកម្មគិតទុកជាមុនដដែល។ នៅក្នុងអំពើនេះ គឺត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ២០០ គឺត្រូវដាក់ពន្ធនាគារអស់មួយជីវិតតែម្តង។

**គ.បទប្បញ្ញត្តិដែលចែងពីរូបភាពនៃឃាតកម្មគិតទុកជាមុន**

នៅក្នុងការបកស្រាយចំពោះធាតុសត្យានុម័ត នៃបទល្មើសឃាតកម្មគិតទុកជាមុននៅក្នុងច្បាប់ថ្មីនេះ យើងសូមលើកយកនូវច្បាប់ជាធរមានពីរ គឺក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ និងច្បាប់ស្តីពី ការគ្រប់គ្រងអាស៊ីដខ្លាំង ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១១។ នៅក្នុងច្បាប់ទាំងពីរនេះមានបទល្មើសមួយចំនួនដែលត្រូវបានចាត់ទុកដូចជាបទឃាតកម្មគិតទុកជាមុនផងដែរ គឺបទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំងដែលប៉ះពាល់ដល់អាយុជីវិតមនុស្សដោយចេតនា និងបទរាជឃាតកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

**គ.១.ច្បាប់ស្តីការគ្រប់គ្រងអាស៊ីដខ្លាំង**

បានជាយើងលើកយកច្បាប់ស្តីពីអាស៊ីដខ្លាំងមកបង្ហាញ គឺគ្រាន់តែបញ្ជាក់អំពីមធ្យោបាយនៃការប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសនេះតែប៉ុណ្ណោះ ដើម្បីបញ្ជាក់ថាបទល្មើសដែលប្រើប្រាស់អាស៊ីដជាមធ្យោបាយនេះ ក៏មានរូបភាពនៃការប្រព្រឹត្តនៅក្នុងបទឃាតកម្មគិតទុកជាមុនដែរ ។ យើងអាចពិនិត្យទៅលើមាត្រាជាក់ស្តែងនៅក្នុងច្បាប់នេះ ដែលមានចែងអំពីការគិតទុកជាមុន និងការពួនស្ទាក់ ដែលជាសញ្ញាណនៃបទឃាតកម្មគិតទុកជាមុនផងដែរ ។ ការចែងនេះមាននៅក្នុងមាត្រា ១៦ ចែងថា « អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាស៊ីដខ្លាំង ត្រូវបានផ្តន្ទាទោសពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីបទឧក្រិដ្ឋខាងលើត្រូវបានប្រព្រឹត្តដោយមាន៖

- ការគិតទុកជាមុន ឬការពួនស្ទាក់
- អំពើទារុណកម្ម ឬអំពើឃោរឃៅមុន ឬក្នុងពេលប្រព្រឹត្តអំពើសម្លាប់។

ចំពោះបទឧក្រិដ្ឋខាងលើ ទោសបន្ថែមដែលមានចែងក្នុងមាត្រា ២០៦ (ទោសបន្ថែមៈប្រភេទ និងរយៈពេល) នៃក្រមព្រហ្មទណ្ឌអាចត្រូវបានប្រកាស ។»

**គ.២.បទរាជឃាតកម្ម**

ចំណែកឯនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ក៏បានចែងពីទម្រង់នៃឃាតកម្មគិតទុកជាមុនដែរ គឺមាត្រា ៤៣៣ បទរាជឃាតកម្ម បានចែងថា "រាជឃាតកម្ម គឺជាឃាតកម្មចំពោះអង្គព្រះមហាក្សត្រ ។ រាជឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។"

បានជាយើងថាបទរាជឃាតកម្ម ជាបទឃាតកម្មគិតទុកជាមុនដោយសារតែមុននឹងជនល្មើសធ្វើឃាតអង្គព្រះមហាក្សត្រ ពេលខ្លះក៏មិនអាចធ្វើការសម្រេចចិត្ត ហើយធ្វើការប្រព្រឹត្តភ្លាមៗបាននោះដែរ គឺត្រូវតែមានការរៀបចំគម្រោងគិតទុកជាមុន ។

### ២.២.៣. ធាតុផ្សំអត្តនោម័ត

នៅក្នុងធាតុផ្សំអត្តនោម័តនៃបទឃាតកម្មនេះ យើងក៏លើកយកនូវច្បាប់ចំនួនពីរមកធ្វើការបកស្រាយផងដែរ គឺច្បាប់ចាស់ និងច្បាប់ថ្មី ។

#### ២.២.៣.១. ច្បាប់ចាស់

ធាតុអត្តនោម័តក្នុងអំពើមនុស្សឃាតគិតទុកជាមុន គឺមានលក្ខណៈដូចគ្នានៅក្នុងធាតុអត្តនោម័តនៅក្នុងអំពីមនុស្សឃាតដោយចេតនាដែរ។ ប៉ុន្តែអ្វីដែលខុសគ្នារវាងបទល្មើសទាំងពីរ គឺជា

ចេតនាទុច្ចរិតនៅក្នុងអំពើ មនុស្សឃាតគិតទុកជាមុន គឺជាប្រភេទចេតនាទុច្ចរិតធ្ងន់ធ្ងរដែលជាមូលហេតុនាំអោយអំពើមនុស្សឃាតគិតទុកជាមុន ត្រូវបានផ្តន្ទាទោសធ្ងន់ធ្ងរជាងអំពើមនុស្សឃាតដោយចេតនា។

**២.២.៣.២. ច្បាប់ថ្មី**

ធាតុសត្យានុម័ត និងធាតុអត្តនោម័ត គឺដូចគ្នាទៅនឹងអំពើឃាតកម្មដែរ ខុសត្រង់ថា ឃាតកម្មគិតទុកជាមុន គឺមានគំរោងទុកជាស្រេចថានឹងសម្លាប់ដោយមានត្រៀមមធ្យោបាយ ឬ ឧបករណ៍ ផ្សេងៗ ក្នុងគោលបំណងបង្កឱ្យគ្រោះថ្នាក់ដល់ជីវិត និងមានការពួនស្ទាក់ ដោយឃ្លាំចាំជនណាម្នាក់ក្នុងរយៈពេលមួយ(យូរ ឬឆាប់ក្តី) នៅកន្លែងណាមួយដើម្បីសម្លាប់ជននោះ។

## ២.៣ ទោសដែលត្រូវអនុវត្ត

ទោសដែលត្រូវយកមកអនុវត្តទៅលើបទឃាតកម្មគិតទុកជាមុន មានចំនួនពីរ គឺមូលទោស និងទោសបន្ថែម ។

### ២.៣.១ មូលទោស

មូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យ។

មូលទោស គឺជាទោសមូលដ្ឋាន ដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោសត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ (មាត្រា ៤៣)។

**២.៣.១.១.ទោសដាក់ពន្ធនាគារ**

ទោសដាក់ពន្ធនាគារ គឺជាទោសគុក ទោសដែលបំបាត់សេរីភាពមានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ។

**២.៣.១.២.ទោសពិន័យ**

ភ្ជាប់ជាមួយទោសដាក់ពន្ធនាគារ នៅមានទោសមួយទៀតដែលគេឱ្យឈ្មោះថា ទោសពិន័យ ។ ការពិន័យជាប្រាក់ គឺត្រូវគិតជាប្រាក់រៀលដែលជារូបិយវត្ថុជាតិខ្មែរហើយផលដែលបានមកពីការពិន័យជាប្រាក់នេះត្រូវបង់ចូលទៅក្នុងថវិការបស់រដ្ឋ។

### ២.៣.២ ទោសបន្ថែម

ចំពោះបទឃាតកម្មគិទុកជាមុន ទោសបន្ថែមរបស់វាក៏មិនខុសពីទោសបន្ថែមដែលអាចត្រូវបានដាក់ទៅលើមូលទោសនៃបទឃាតកម្មដែរ ។ ទោសបន្ថែមទាំងនោះមានដូចខាងក្រោមៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត នៅក្នុង ការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ខ្ញុំសូមបញ្ចប់នូវការបកស្រាយក្នុងជំពូកទី២ត្រង់ទំព័រនេះ។ បន្ទាប់ពីបានយល់ពីជំពូកទី១ "បទឃាតកម្ម" និង ជំពូកទី២ "បទឃាតកម្មគិតទុកជាមុន" រួចហើយខ្ញុំនឹងយកជំពូកទាំងពីរទៅធ្វើការប្រៀបធៀបពីចំនុចដូច និងចំនុចខុសគ្នាក្នុងជំពូកទី៣ ដូចខាងក្រោមនេះ៖

# ជំពូកទី ៣
# ការប្រៀបធៀបបទល្មើសទាំងពីរ

បន្ទាប់ពីយើងបានធ្វើការបកស្រាយអំពី បទល្មើសទាំងពីរខាងលើ ដែលមានពីរជំពូក គឺនៅក្នុងជំពូកទី ១ បទល្មើសឃាតកម្ម និងជំពូកទី ២ បទល្មើសឃាតកម្មគិតទុកជាមុន រួចហើយយើងអាចសិក្សាទៅលើប្រភេទនៃបទល្មើសទាំងពីរនេះដោយអាចទាញយកនូវចំនុចជាច្រើន ដើម្បីយកមកធ្វើការប្រៀបធៀបគ្នា ។ បើធ្វើការពិនិត្យចំពោះការប្រៀបធៀបទៅលើបទល្មើសទាំងពីរខាងលើនេះ ត្រូវបានយកមកធ្វើការបកស្រាយនៅក្នុងជំពូកទី ៣ នេះដោយធ្វើការបែងចែកជាពីរចំនុចធំៗ គឺទីមួយយើងធ្វើការបកស្រាយទៅលើចំនុចដូចគ្នានៃបទល្មើស(៣.១) និង ចំណុចខុសគ្នានៃបទល្មើស (៣.២) ។

## ៣.១.ចំណុចដូចគ្នា

ការបកស្រាយទៅលើចំនុចដូចគ្នានៃបទល្មើសទាំងពីរ អាចធ្វើឡើងទៅបានដោយឆ្លងកាត់ការសិក្សាការវិភាគ និងការពិនិត្យយ៉ាងស៊ីជម្រៅទៅលើការបកស្រាយទាំងឡាយ ដែលលើកឡើងអំពីបទល្មើសនីមួយៗនៅក្នុងជំពូកទាំងពីរខាងលើ ។ បន្ទាប់ពីបានសិក្សាយ៉ាងយកចិត្តទុកដាក់ទៅលើការបកស្រាយក្នុងជំពូកទី១ បទឃាតកម្ម និងជំពូកទី២បទឃាតកម្មគិតទុកជាមុន យើងអាចលើកយកនូវចំនុចមួយចំនួនដែលមានលក្ខណៈដូចគ្នា ដើម្បីយកមកធ្វើការបកស្រាយដោយបែងចែកជាចំនុចធំៗមួយចំនួនដូចជា៖ ការចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ (៣.១.១) ប្រភេទនៃបទល្មើស(៣.១.២) ជនល្មើស និងជនរងគ្រោះ(៣.១.៣) អំពើ និងបច្ច័យ(៣.១.៤) អាជ្ញាយុកាល (៣.១.៥) និងទោសបន្ថែម និងការប៉ុនប៉ង(៣.១.៦) ។

### ៣.១.១. ការចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ការបកស្រាយចំពោះការចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះ គឺចង់សំដៅទៅលើការបកស្រាយដែលធ្វើការប្រៀបធៀបរវាងបទល្មើសទាំងពីរ ផ្តោតសំខាន់ទៅលើការសិក្សាអំពីទីតាំងនៃបទល្មើសនៅក្នុងក្រមនេះ ។ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះត្រូវបានបង្កើតឡើងក្រោមការរៀបចំនូវរចនាសម្ព័ន្ធដោយ ធ្វើការបែងចែកជាបួនចំណុចតាមលំដាប់លំដោយ គឺគន្ថី មាតិកា ជំពូក និង ផ្នែក ។

បទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន ទីតាំងរបស់បទល្មើសទាំងពីរនេះ គឺស្ថិតនៅក្នុងចំណុចទាំងបួននៃរចនាសម្ព័ន្ធរបស់ក្រមនេះដូចគ្នា ។ យើងសូមលើកយកនូវចំនុចទាំងបួននេះមកធ្វើការបកស្រាយដោយភ្ជាប់ទៅនឹងបទល្មើសទាំងពីរ ដោយបែងចែកជាបួនចំណុចដែរ

គឺការចែងនៅក្នុងគន្ថី(៣.១.១.១) ការចែងនៅក្នុងមាតិកា(៣.១.១.២) ការចែងនៅក្នុងជំពូក(៣.១.១.៣) និងការចែងនៅក្នុងផ្នែក(៣.១.១.៤) ។

**៣.១.១.១.ការចែងនៅក្នុងគន្ថី**

នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នេះត្រូវបានបង្កើតឡើងដោយធ្វើការបែងចែកជា ០៦គន្ថី ដោយគិតចាប់ពីគន្ថីទី១ បទប្បញ្ញត្តិទូទៅ រហូតដល់គន្ថីទី៦ អវសានប្បញ្ញត្តិ ។ ទោះបីជាមានការកំណត់ដល់ទៅ ០៦ គន្ថី ប៉ុន្តែគន្ថីដែលនិយាយពីបទល្មើសមានតែ ០៣ គន្ថីប៉ុណ្ណោះ គឺគន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និង គន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ ។ ចំពោះបទល្មើសឃាតកម្ម និងបទល្មើសឃាតកម្មគិតទុកជាមុន គឺមានចែងនៅក្នុងគន្ថីទី២ បទល្មើសប្រឆាំងនឹងបុគ្គលដូចគ្នា។

មូលហេតុដែលបទល្មើសទាំងពីរនេះចែងនៅក្នុងគន្ថី ដែលលើកឡើងអំពីបទល្មើសប្រឆាំងនឹងបុគ្គល ដោយសារតែបទល្មើសទាំងពីរ គឺជាអំពើសម្លាប់ ហេតុនេះអំពើសម្លាប់អាចធ្វើទៅបានតែចំពោះរូបវន្តបុគ្គលតែប៉ុណ្ណោះវាមិនអាចធ្វើទៅលើទ្រព្យសម្បត្តិ ឬទៅលើជាតិបានទេ។

**៣.១.១.២.ការចែងនៅក្នុងមាតិកា**

**មាតិកា** គឺជាចំណុចមួយដែលស្ថិតនៅលំដាប់បន្ទាប់ពីគន្ថី ហើយនៅក្នុងគន្ថីនីមួយៗ អាចមានការកំណត់នូវមាតិកាច្រើន ឬតិចវាអាស្រ័យទៅតាមវិសាលភាពនៃគន្ថីនោះ ។ គន្ថីទី ២ នេះមានការបែងចែកជា ០៣ មាតិកា ហើយបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ត្រូវបានចែងកំណត់នៅក្នុងមាតិកាទី ២ ការប៉ះពាល់ដល់មនុស្ស។

ចំពោះមូលហេតុដែលបទល្មើសទាំងពីរ ត្រូវបានចែងកំណត់ក្នុងមាតិកានេះ ពីព្រោះតែវាជាអំពើសម្លាប់ ហើយនៅក្នុងក្រមនេះបានកំណត់អំពីអំពើសម្លាប់ដែលជាបទល្មើស។ អំពើសម្លាប់នេះគឺត្រូវតែធ្វើឡើងទៅលើមនុស្ស មិនអាចធ្វើទៅលើអ្វីផ្សេងដូចជា សត្វ ឬវត្ថុ ឬទ្រព្យបានទេ ។

**៣.១.១.៣. ការចែងនៅក្នុងជំពូក**

**ជំពូក** គឺជាចំណុចមួយដែលស្ថិតនៅក្នុងលំដាប់បន្ទាប់ពីមាតិកា ហើយនៅក្នុងមាតិកាទី២ នេះក៏មានការបែងចែកជាច្រើនជំពូកផងដែរ ។ នៅក្នុងមាតិកាទី២ នេះត្រូវបានបែងចែកជា ៦ ជំពូក ហើយបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ត្រូវបានចែងនៅក្នុងជំពូកទី១ ការប៉ះពាល់ដល់ជីវិតមនុស្ស ។

បានជាបទល្មើសទាំងពីរនេះ ត្រូវបានចែងនៅក្នុងជំពូកនេះ ពីព្រោះតែបទល្មើសទាំងពីរនេះវាបណ្តាលឱ្យមានការប៉ះពាល់ដល់ជីវិតមនុស្សតាមរយៈអំពើសម្លាប់មនុស្ស ឬផ្តាច់ជីវិតមនុស្ស ឬប្រល័យជីវិតមនុស្ស ។

### ៣.១.១.៤. ការចែងនៅក្នុងផ្នែក

**ផ្នែក** គឺ ជាចំណុចចុងក្រោយនៃរចនាសម្ព័ន្ធដែលមាននៅក្នុងក្រមនេះ ហើយនៅក្នុងជំពូកទី ១ នេះត្រូវបានបែងចែកជា ២ ផ្នែក ។ ផ្នែកទី ១ ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស និងផ្នែកទី ២ ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស ហើយបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ត្រូវបានចែងនៅក្នុងផ្នែកទី ១ ។

បទល្មើសទាំងពីរនេះ ត្រូវបានចែងនៅក្នុងផ្នែកនេះដោយសារ បទល្មើសទាំងពីរនេះកើតឡើងដោយ ឆន្ទៈរបស់ចារី ឬជនល្មើសដែលមានចេតនាក្នុងការចង់សម្រេចឱ្យមានបទល្មើសមួយកើតឡើង ។ ការលើកឡើងបែបនេះ គឺមានន័យថាអំពើណាមួយអាចចាត់ទុកថាជាបទល្មើសណាមួយទាំងពីរខាងលើនេះ លុះត្រាតែអំពើនោះត្រូវបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ ហើយកើតចេញពីចេតនាផ្ទាល់របស់បុគ្គលនោះផងដែរ បើមិនកើតឡើងដោយចេតនាទេ នោះវានឹងក្លាយទៅជាបទល្មើសមួយផ្សេងទៀត ។

### ៣.១.២.ប្រភេទនៃបទល្មើស

នៅក្នុងចំណុចនេះ យើងធ្វើការបកស្រាយទៅលើប្រភេទនៃបទល្មើស ចំពោះបទល្មើសទាំងពីរ ដើម្បីឱ្យដឹងថាបទល្មើសទាំងពីរនេះស្ថិតនៅក្នុងប្រភេទនៃបទល្មើសមួយណា ។ បទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ត្រូវបែងចែកជាបីប្រភេទ គឺជាបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ដើម្បីឱ្យយើងអាចធ្វើការកំណត់ប្រភេទនៃបទល្មើសចំពោះបទល្មើសទាំងពីរ យើងត្រូវធ្វើការពិនិត្យទៅលើនិយមន័យប្រភេទនៃបទល្មើសនីមួយៗដូចខាងក្រោម៖

***បទលហុ*** សំដៅទៅលើបទល្មើសទាំងឡាយណាដែលបានបំពេញទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

១. អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២. បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ [9]។

***បទមជ្ឈិម*** សំដៅទៅលើបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនេះ មានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬស្មើនឹង ៥ ឆ្នាំ ហើយអាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ [10]។

[9] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

[10] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

***បទឧក្រិដ្ឋ*** សំដៅទៅលើបទល្មើសទាំងឡាយណាដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនេះ៖

១.ជាទោសទោសដាក់ពន្ធនាគារអស់មួយជីវិត

២.ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ ឆ្នាំ ។ ហើយក្រៅពីទោសដាក់ពន្ធនាគារ ក៏អាចត្រូវបានបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[11] ។

បន្ទាប់ពីបានពិនិត្យទៅលើនិមយន័យនូវប្រភេទទាំងបីនៃបទល្មើសខាងលើ យើងសង្កេតឃើញថា បទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន គឺស្ថិតនៅក្នុងប្រភេទនៃបទឧក្រិដ្ឋ ។ បានជាយើងសន្និដ្ឋានដូច្នេះ ពីព្រោះតែអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងបទល្មើសទាំងពីរ ស្របតាមលក្ខខណ្ឌនៃបទឧក្រិដ្ឋ គឺបទឃាតកម្ម ទោសដាក់ពន្ធនាគារ ពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ(ចូលទៅក្នុងលក្ខខណ្ឌទី២ នៃមាត្រា៥៦ ព្រោះអតិបរមានៃទោសដាក់គុកគឺ ១៥ឆ្នាំ ដូច្នេះវាលើសពី ៥ឆ្នាំ) និងបទឃាតកម្មគិតទុកជាមុន ទោសដាក់ពន្ធនាគារអស់មួយជីវិត (ចូលទៅក្នុងលក្ខខណ្ឌទី១ នៃមាត្រា៥៦)។

### ៣.១.៣.បុគ្គលដែលពាក់ព័ន្ធទៅនឹងបទល្មើស

នៅក្នុងករណីមួយដែលជាបទល្មើស គឺបង្កើតឡើងដោយបុគ្គលទៅលើបុគ្គលផ្សេងទៀត ដែលបង្ករការខូចខាតដល់បុគ្គលដែលរងគ្រោះ។ ចំពោះបុគ្គលដែលជាប្រធាននៃបទល្មើសត្រូវបានបែងចែកជាពីរប្រភេទ គឺ រូបវន្តបុគ្គល និងនីតិបុគ្គលដោយយោងទៅតាមក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានធ្វើការកំណត់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិបុគ្គលដែលជាសញ្ញាណថ្មីមួយ ដែលពីមុនមកពុំមានកំណត់នៅក្នុងច្បាប់ចាស់ឡើយ ។

ចំពោះប្រធាននៃបទល្មើស នៅក្នុងបទឃាតកម្ម និងឃាតកម្មគិតទុកជាមុន គឺមានតែរូបវន្តបុគ្គលតែប៉ុណ្ណោះដែលត្រូវទទួលខុសត្រូវ ពុំមាននីតិបុគ្គលនោះទេ ហេតុដូច្នេះនៅក្នុងចំណុចនេះ យើងសូមធ្វើការបកស្រាយទៅលើតែរូបវន្តបុគ្គលប៉ុណ្ណោះ ។ រូបវន្តបុគ្គលដែលជាប្រធាននៃបទល្មើសទាំងពីរនេះ ដោយមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទល្មើសមានពីរ គឺជនល្មើស និងជនរងគ្រោះ ។

#### ៣.១.៣.១.ជនល្មើស

ជនល្មើស ឬយើងអាចហៅម្យ៉ាងទៀតថា ចារីសំដៅទៅលើបុគ្គលដែលមានលក្ខណៈដូចខាងក្រោម៖

[11] មាត្រា ៥៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

- បុគ្គលប្រព្រឹត្តបទល្មើស ដែលត្រូវចោទប្រកាន់
- បុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ
- បុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមក្នុងករណីដែលច្បាប់បានចែងទុក [12]។

ជនល្មើស ឬចារី អាចជាបុគ្គលតែម្នាក់ ហើយក៏អាចមានបុគ្គលច្រើននាក់ដែរ មានបុគ្គលច្រើននាក់ចូលរួម យើងហៅថា សហចារី ។ ក្រៅពីនេះពេលខ្លះអាចមានទាំងអ្នកផ្តើមគំនិត ឬអ្នកសមគំនិតផងដែរ។

**៣.១.៣.២.ជនរងគ្រោះ**

យើងសូមលើកយកនូវអត្ថន័យនៃជនរងគ្រោះមកបង្ហាញ មុននឹងឈានទៅដល់ការបញ្ជាក់ផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ។ ជនរងគ្រោះមានន័យថា៖

- តាមន័យក្រមព្រហ្មទណ្ឌ ជនទទួលរងដោយផ្ទាល់នូវព្យសនកម្មដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌ ។
- តាមន័យទូទៅ ជនទទួលរងការឈឺចាប់ដោយអំពើខុសច្បាប់ដែលនាំឱ្យខូចសេចក្តីថ្លៃថ្នូរ កិត្តិយស បញ្ញាស្មារតី រូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន[13] ។

ប៉ុន្តែនៅក្នុងការបកស្រាយចំណុចនេះ យើងត្រូវពិនិត្យទៅលើអត្ថន័យតាមក្រមព្រហ្មទណ្ឌ ។ នៅក្នុងបទល្មើសទាំងពីរខាងលើនេះ យើងត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះនេះ ពីព្រោះលក្ខខណ្ឌនេះអាចជួយឱ្យយើងធ្វើការកំណត់នូវអាទិភាពនៃបទល្មើសទាំងពីរនេះបានដែលលក្ខខណ្ឌទាំងនោះមានដូចខាងក្រោម៖

- ត្រូវមានអត្ថិភាពនៃជនរងគ្រោះ គឺត្រូវរកឱ្យឃើញថាមានជនរងគ្រោះពិតប្រាកដ
- ជនរងគ្រោះ គឺជាអ្នកដទៃដែលផ្សេង ឬក្រៅពីជនល្មើស ទោះបីជាសាច់ញាតិក៏ដោយ មានន័យថាជនរងគ្រោះមិនអាចជាជនល្មើសនោះទេ ពីព្រោះប្រសិនបុគ្គលម្នាក់បានប្រព្រឹត្តនូវអំពើសម្លាប់ទៅលើខ្លួនឯង នេះមិនចាត់ទុកថា ជាបទល្មើសទាំងពីរនេះទេ ។
- ជនរងគ្រោះត្រូវតែមានជីវិតនៅពេលមានបទល្មើសកើតឡើង ប្រសិនបើអំពើសម្លាប់បានធ្វើឡើងទៅលើបុគ្គលដែលគ្មានជីវិត ដែលយើងហៅសាកសពនោះ អំពើ

[12] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្តីការរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០០១ លេខរៀងទី ៣៨

[13] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្តីការរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០០១ លេខរៀងទី ៤០

សម្លាប់នោះមិនមែនជាបទល្មើសទាំងពីរនេះទេ វាបានក្លាយទៅជាបទល្មើសមួយផ្សេងដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ (យោងតាមមាត្រា២៦១ បទប៉ះពាល់ដល់បូរណភាពនៃសាកសព) ។

### ៣.១.៤.អំពើ និងបច្ច័យ

អំពើ និងបច្ច័យ គឺជាចំណុចសំខាន់ដែលយើងត្រូវពិចារណានៅក្នុងបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ហើយទាំងពីរចំណុចនេះមានលក្ខណៈផ្ទុយគ្នាដូចខាងក្រោម៖

អំពើ៖ នៅក្នុងបទល្មើសទាំងពីរនេះ អំពើ គឺជាធាតុដ៏សំខាន់បំផុតដែលត្រូវតែមាន ហើយអំពើនោះត្រូវតែជាអំពើសម្លាប់មនុស្ស ឬផ្ដាច់ជីវិតមនុស្ស ឬប្រល័យជីវិតមនុស្ស ដែលមានន័យថា គឺជាអំពើដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្ស ។ អំពើសម្លាប់ គឺជាសញ្ញាណដាច់ខាតនៅក្នុងបទល្មើសទាំងពីរនេះ ប្រសិនបើពុំមានអំពើណាមួយដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្សទេ គឺពុំមានបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងពីរកើតឡើងឡើយ ។

បច្ច័យ៖ សំដៅទៅលើផលដែលកើតចេញពីបទល្មើស ប៉ុន្តែចំពោះបទល្មើសទាំងពីរនេះមិនទាមទារថាទាល់តែជនរងគ្រោះស្លាប់បាត់បង់ជីវិតនោះទេ ។ បច្ច័យ នៅក្នុងបទល្មើសទាំងពីរនេះ គឺជាសញ្ញាណមិនដាច់ខាតទេ មានន័យថា ការស្លាប់បាត់បង់ជីវិតរបស់ជនរងគ្រោះមិនមែនជាធាតុសំខាន់ក្នុងការកំណត់នូវបទល្មើសឡើយ ។

សរុបសេចក្ដីមក នៅក្នុងបទល្មើសទាំងពីរនេះ គឺទាមទារឱ្យមានអំពើដែលផ្ទុកនូវលទ្ធភាពដកហូតជីវិតមនុស្សដោយផ្ទុយនឹងច្បាប់ជាដាច់ខាត ហើយមិនតម្រូវឱ្យមានការស្លាប់បាត់បង់ជីវិតកើតឡើងទេ ។

### ៣.១.៥.អាជ្ញាយុកាល

អាជ្ញាយុកាលមានន័យថា ជារយៈពេលដែលមានសិទ្ធិប្ដឹង រយៈពេលដែលដើមបណ្ដឹងព្រហ្មទណ្ឌមានសិទ្ធិប្ដឹងពីជនល្មើស ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[14] ។ អាជ្ញាយុកាលនៅក្នុងរឿងព្រហ្មទណ្ឌត្រូវបានបែងចែកជាពីរប្រភេទ គឺអាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស ។

#### ៣.១.៥.១.អាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស ឬយើងអាចហៅម្យ៉ាងទៀតថា អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាមានន័យថា ជារយៈពេលដែលកំណត់អំពីអត្ថិភាព នៃបទល្មើសដែលបានកើតឡើងហើយដោយ

[14] យោងតាមសទ្ទានុក្រមពាក្យច្បាប់ក្រមព្រហ្មទណ្ឌទីស្ដីការរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០០១ លេខរៀងទី ២៣៧

សារតែរយៈពេលនេះអាចឱ្យអ្នកដែលមានសិទ្ធិប្តឹង អាចធ្វើការប្តឹងអំពីបទល្មើសណាមួយចំពោះបុគ្គលដែលខ្លួនចង់ប្តឹងបន្ទាប់ពីមានបទល្មើសកើតឡើង ។ បន្ទាប់ពីមានបទល្មើសមួយកើតឡើង រយៈពេលនៃសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ត្រូវគិតចាប់ពេលនោះមក ហើយប្រសិនបើអ្នកដែលមានសិទ្ធិប្តឹងមិនបានដាក់ពាក្យបណ្តឹងនៅក្នុងរយៈនោះទេ បណ្តឹងអាជ្ញាត្រូវរលត់ នៅពេលដែលបណ្តឹងអាជ្ញាត្រូវរលត់ សិទ្ធិប្តឹងក៏ត្រូវរលត់ដែរ ហើយការប្តឹងមិនអាចធ្វើទៅបានទៀតឡើយ។ ថិរវេលានៃអាជ្ញាយុកាលត្រូវបានកំណត់ទៅតាមប្រភេទ ឬចំណាត់ថ្នាក់នៃបទល្មើស ដែលមានរយៈពេលខុសៗគ្នា ។ ប្រភេទ ឬចំណាត់ថ្នាក់នៃបទល្មើសមានបីប្រភេទ គឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ហើយថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖

- ១៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ឆ្នាំ ចំពោះបទលហុ[15]

បើយើងពិនិត្យទៅលើអាជ្ញាយុកាលនៃបទល្មើសខាងលើយើងសង្កេតឃើញថាបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនមានអាជ្ញាយុកាលដូចគ្នា គឺថិរវេលា ១៥ ឆ្នាំ ពីព្រោះតែបទល្មើសទាំងពីរនេះស្ថិតនៅក្នុងប្រភេទ ឬចំណាត់ថ្នាក់នៃបទឧក្រិដ្ឋ ។

**៣.១.៥.២.អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស មានន័យថា ជារយៈពេលដែលកំណត់អំពីអត្ថិភាពនៃទោសដែលអាចយកទៅអនុវត្តបានចំពោះទណ្ឌិតដែលត្រូវបានប្រកាសដោយតុលាការ។ នៅពេលដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរហើយ ទោះបីជាតាមរូបភាពជាសាលក្រម ឬសាលដីកាក៏ដោយ ទោសដែលត្រូវបានសម្រេច ប្រកាសដោយតុលាការនោះ ត្រូវតែយកមកអនុវត្ត ។ នៅក្នុងរយៈពេលដែលជាអត្ថិភាពនៃទោស តុលាការអាចចាប់ខ្លួនពិរុទ្ធជនឱ្យមកទទួលទោសបាន ប៉ុន្តែប្រសិនបើមិនបានចាប់ខ្លួន ឬជននោះបានគេចខ្លួនរហូតដល់ផុតរយៈពេលនេះតុលាការមិនអាចចាប់ខ្លួនជននោះមកទទួលទោសបានទៀតឡើយ។ ហើយទោសនោះទុកជាអាសារសូន្យ ឬអាសារបង់។

ថិរវេលានៃអាជ្ញាយុកាលនៃទោស ក៏មិនខុសពីរអាជ្ញាយុកាលនៃបទល្មើសដែរ គឺត្រូវបានកំណត់ទៅតាមចំណាត់ថ្នាក់នៃបទល្មើសនីមួយៗ ។ ថិរវេលានៃអាជ្ញាយុកាលនេះត្រូវបានកំណត់ដូចខាងក្រោម៖

- ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ឆ្នាំ

[15] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

- ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ ឆ្នាំ
- ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ ឆ្នាំ [16]។

បើពិនិត្យទៅលើថិរវេលានេះ បទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន មានថិរវេលានៃអាជ្ញាយុកាលនេះដូចគ្នា គឺ ២០ ឆ្នាំ ពីព្រោះបទល្មើសទាំងពីរនេះសុទ្ធជាបទឧក្រិដ្ឋដូចគ្នា។

### ៣.១.៦.ទោសបន្ថែម និងការប៉ុនប៉ង

ក្រៅពីចំណុចដូចគ្នាជាច្រើនខាងលើក៏នៅមានចំណុចដូចគ្នាចំនួនពីរផ្សេងទៀត គឺចំណុចដែលពាក់ព័ន្ធទៅនឹងទោសបន្ថែម និងការប៉ុនប៉ង ។ យើងអាចពិនិត្យទៅលើចំណុចដូចគ្នាទាំងពីរបានតាមរយៈមាត្រាជាក់ស្តែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

- ទោសបន្ថែម អាចប្រកាសបានដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២០៦ នៃក្រមព្រហ្មទណ្ឌ
- ការប៉ុនប៉ង ដោយសារតែបទល្មើសទាំងពីរជាបទល្មើសឧក្រិដ្ឋដូចគ្នា ហេតុនេះហើយការប៉ុនប៉ងនៃបទល្មើសទាំងពីរនេះ គឺត្រូវយោងទៅតាមមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ហើយការប៉ុនប៉ងនេះពុំមានចែងនៅក្នុងផ្នែកនៃបទល្មើសទាំងពីរនេះទេ។

## ៣.២.ចំណុចខុសគ្នា

ស្រដៀងគ្នាទៅនឹងការបកស្រាយ ទៅលើចំនុចដូចគ្នានៃបទល្មើសទាំងពីរនេះផងដែរ ការបកស្រាយអំពីចំនុចខុសគ្នានៃប្រភេទទោស អាចធ្វើឡើងបានតាមរយៈការសិក្សាទៅលើការបកស្រាយអំពីបទល្មើសនីមួយៗផងដែរ។ បន្ទាប់ពីបានពិនិត្យដោយយកចិត្តទុកដាក់ទៅលើការរៀបរាប់នូវបទល្មើសទាំងពីររួចហើយ យើងអាចធ្វើការកត់សម្គាល់នូវចំនុចខុសគ្នាមួយចំនួនរវាងបទល្មើសទាំងពីរ ។ ការបកស្រាយទៅលើចំនុចខុសគ្នានៃបទល្មើស ត្រូវបានបង្ហាញតាមរយៈ ការបកស្រាយទៅលើចំនុចធំៗមួយចំនួនដូចជា៖ (និយមន័យនៃបទល្មើសទាំងពីរ)៣.២.១ (ធាតុផ្សំនៃបទល្មើសទាំងពីរ) ៣.២.២ (និងទោសដែលត្រូវទទួលរងនៃបទល្មើសទាំងពីរ) ៣.២.៣។

### ៣.២.១.និយមន័យនៃបទល្មើសទាំងពីរ

**បទឃាតកម្ម** គឺជាអំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្ម ដោយមានទារុណកម្មអំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជា**ឃាតកម្ម** ។

[16] មាត្រា ១៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

**បទឃាតកម្មគិតទុកជាមុន គឺ** ជាអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការពួនស្ទាក់ ។

-***ការគិតទុកជាមុន*** គឺជាគម្រោង ឬ ការរៀបចំនូវផែនការ សកម្មភាព ជាសេនារីយោ ដែលបង្កើត ឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ(រូបវន្តបុគ្គល) ។

-***ការពួនស្ទាក់*** គឺជាអំពើឃ្លាំមើលចាំបុគ្គលណាម្នាក់ ដោយស្គាល់អត្តសញ្ញាណជននោះច្បាស់លាស់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះជារូបវន្តបុគ្គល ហើយបើទោះបីជាមានការភ័ន្តច្រឡំទៅលើជនរងគ្រោះក៏ដោយ ។

### ៣.២.២.ធាតុផ្សំនៃបទល្មើសទាំងពីរ

យោងតាមមូលដ្ឋានគ្រឹះនៃនីតិព្រហ្មទណ្ឌទូទៅ យើងអាចយកមកធ្វើការសិក្សានៅក្នុងនីតិព្រហ្មទណ្ឌពិសេសដោយផ្អែកទៅលើធាតុផ្សំចំនួន ០៣ (បី) គឺធាតុផ្សំនីត្យានុកូល ឬ ធាតុផ្សំផ្អែកច្បាប់ (៣.២.២.១), ធាតុផ្សំសត្យានុម័ត ឬធាតុផ្សំសម្ភារៈ (៣.២.២.២) និង ធាតុផ្សំអត្តនោម័ត ឬ ធាតុផ្សំចិត្តសាស្ត្រ (៣.២.២.៣) ៖

#### ៣.២.២.១.ធាតុផ្សំនីត្យានុកូល

ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់ សំដៅទៅលើការចែងអំពីបទល្មើសនីមួយៗនៅក្នុងច្បាប់ជាធរមាន ចំពោះបទល្មើសទាំងពីរនេះ ត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ។

- បទឃាតកម្មមានចែងនៅក្នុងមាត្រា ១៩៩
- បទឃាតកម្មគិតទុកជាមុនមានចែងនៅក្នុងមាត្រា ២០០

#### ៣.២.២.២.ធាតុផ្សំសត្យានុម័ត

ធាតុផ្សំសត្យានុម័តនេះបើយើងហៅសាមញ្ញថាជាធាតុសម្ភារៈ មានន័យថា ជាសកម្មភាពដែលកើតចេញរួចធ្វើឱ្យគេអាចសង្កេតឃើញជាសម្ភារៈខាងក្រៅ ។ ហេតុនេះហើយបានជានៅក្នុងទ្រឹស្តី គេតែងហៅថាធាតុផ្សំសត្យានុម័ត គឺជាធាតុសម្ភារៈនៃបទល្មើស[17] ។

##### ក.អំពើនៃការគិតទុកជាមុន និងការពួនស្ទាក់

បទឃាតកម្មបានន័យថា ជនល្មើសសម្លាប់គេ គឺមិនបានរៀបចំគម្រោងអ្វីមុននោះទេ ឬ មិនបានទៅចាំអ្នកណាម្នាក់ ក្នុងពេលមួយរយៈដើម្បីសម្លាប់ជនរងគ្រោះនោះឡើយ ។

[17] ប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើង ដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ ២០១០

ចំពោះបទឃាតកម្មគិតទុកជាមុន បានសេចក្តីថាជនល្មើសមុននឹងទៅសម្លាប់ជនរងគ្រោះ គឺគាត់បានរៀបចំគម្រោង រៀបចំផែនការ រៀបចំសកម្មភាព ជាមុនយ៉ាងច្បាស់លាស់ ឬ បានទៅអង្គុយចាំជនរងគ្រោះណាម្នាក់ ក្នុងពេលណា មួយរយៈដោយស្គាល់អ្នកនោះច្បាស់ថាត្រូវតែសម្លាប់អ្នកនោះចោលតែម្តង ។

**ខ.លទ្ធផលនៃការប្រព្រឹត្ត**

លទ្ធផលនៃការប្រព្រឹត្តនេះ មានន័យថាភាពអាចទទួលបានជោគជ័យនៃការប្រព្រឹត្តបទល្មើស ហើយខាងក្រោមនេះ យើងលើកឡើងនូវភាពខុសគ្នាចំពោះលទ្ធភាពនៃការប្រព្រឹត្តនេះ រវាងបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ។

បទឃាតកម្ម ចំពោះអំពើដែលបានប្រព្រឹត្តនេះអាចមិនទទួលបានលទ្ធផលជោគជ័យ ឬ សម្រេច១០០%នោះទេ ពីព្រោះតែនៅក្នុងបទឃាតកម្ម ពេលខ្លះដោយសារតែមិនបានគិតទុកជាមុន ក៏បណ្តាលឱ្យលទ្ធផលអត់បានសម្រេចដូច ក្តីបំណងប្រាថ្នានៃជនល្មើសចង់បានឡើយ ។

<u>ឧទាហរណ៍</u> ៖ ជនល្មើសដកកាំភ្លើងបាញ់ក្បាលជនរងគ្រោះ ដោយសារតែមិនបានពិនិត្យគ្រាប់កាំភ្លើង ជាមុនឱ្យបានត្រឹមត្រូវ, នៅពេលបាញ់ចេញទៅ ស្រាប់តែគ្រាប់កាំភ្លើងនោះស្អុយ ទើបបាញ់មិនចេញគ្រាប់ ហេតុនេះមិនបណ្តាលឱ្យជនរងគ្រោះស្លាប់ឡើយ។

ចំណែកឯបទឃាតកម្មគិតទុកជាមុនវិញ អំពើដែលបានប្រព្រឹត្តនេះអាចទទួលបានលទ្ធផលសម្រេចសឹងតែ ១០០ % ពីព្រោះបទឃាតកម្មគិតទុកជាមុន លទ្ធផលរបស់វា គឺស្ទើរតែ១០០%ទៅហើយដែលបានសម្រេចនោះ ហើយកម្រនឹងបរាជ័យខ្លាំងណាស់សម្រាប់អំពើដែលមានចរិតគ្រោះថ្នាក់ធ្ងន់ធ្ងរបែបៗនេះ ។

<u>ឧទាហរណ៍</u> ៖ មុននឹងជនល្មើសចង់បាញ់ជនរងគ្រោះ គឺគាត់បានពិនិត្យមើលគ្រាប់កាំភ្លើងរួចរាល់អស់ហើយថាស្អុយឬអត់ និងដឹងច្បាស់ថាត្រូវបាញ់ឱ្យចំក្បាល ឬបេះដូងថែមទៀតទើបគេស្លាប់នោះ។

**គ.ពេលវេលានៃការប្រព្រឹត្តអំពើ**

ពេលវេលានៃការប្រព្រឹត្តនេះ គឺចង់សំដៅទៅលើរយៈពេលដែលឈានទៅដល់ការប្រព្រឹត្តបទល្មើស ហើយបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុនមានរយៈពេលខុសគ្នាដូចខាងក្រោម៖

បទឃាតកម្ម រយៈពេលនៃអំពើសត្យានុម័តអាចកើតឡើងភ្លាមៗ ឬប្រព្រឹត្តភ្លាមៗតែម្តង មិនបានកើតឡើងដោយឆ្លងកាត់រយៈពេលមួយដែលសមស្របនោះទេ ។

ឧទាហរណ៍ ៖ នាពេលរាំធុងបាស់ គឺកើតមានការជាន់ជើងគ្នា គ្រាន់តែប៉ុណ្ណឹងក៏ទាស់ទែងនឹងគ្នា ហើយនៅពេលដែលជនល្មើសឃើញដំបងនៅក្បែរនោះ ក៏ស្រាប់តែទាញយកមកដាក់ចំបង្ហើយក្រោយរបស់ ជនរងគ្រោះបណ្តាលឱ្យស្លាប់ភ្លាមៗមួយរំពេចបាត់ទៅ ។

បើយើងពិនិត្យទៅលើបទឃាតកម្មគិតទុកជាមុនវិញ អំពើដែលជាសត្យានុម័តរបស់វានេះ អាចកើតឡើងដោយឆ្លងកាត់ពេលមួយរយៈ ដែលជនល្មើសមានរយៈពេលក្នុងការគិត និងរៀបចំគម្រោងដើម្បីប្រព្រឹត្តបទល្មើសនេះ ។

ឧទាហរណ៍ ៖ ដូចជាករណី **ក** និង **ខ** មានគ្រោះថ្នាក់ចរាចរណ៍ រួចឈ្លោះគ្នាតឹងសរសៃក ហើយចង្អុលមុខគ្នាមួយសន្ទុះ ពួកគាត់ក៏ឡើងចេញទៅបើកឡានរៀងៗខ្លួនបាត់ទៅ ។ លុះក្រោយមក **ក** គិតថាតាំងពីកើតពោះម៉ែខ្ញុំមកមិនដែលឃើញអ្នកណាព្រហើនដូចអាមួយហ្នឹងទេ ហ៊ានមកចង្អុលមុខឯង យើងគិតថាលែងចង់ឱ្យឃើញមុខវាតទៅទៀតនៅលើផែនដីនេះហើយ ទុកឱ្យវារស់នៅក្នុងលោកនេះទៀតមិនកើតទេ ។ គ្រាន់តែជិះឡានបានប្រហែលជា ៤ ទៅ ៥ រយម៉ែត្រក៏បត់ឡានតាមទៅរក **ខ** វិញដល់ពេលឃើញ **ខ** ក៏ទាញកាំភ្លើងបាញ់ផ្ទងៗរហូតដល់គេស្លាប់បាត់បង់ជីវិតទៅ ។

**ឃ.មូលហេតុនៃការប្រព្រឹត្តអំពើ**

ការបកស្រាយទៅលើមូលហេតុនៃការប្រព្រឹត្តនេះ គឺចង់សំដៅទៅលើការលើកឡើងនូវស្ថានភាពដែលអាចបង្ករឱ្យបុគ្គលណាមួយឈានទៅដល់ការប្រព្រឹត្តបទល្មើសជាពិសេស គឺពាក់ព័ន្ធទៅនឹងស្មារតី និងការគិតរបស់បុគ្គលនោះ ។ បើយើងពិនិត្យទៅលើបទឃាតកម្ម និងឃាតកម្មគិតទុកជាមុន ចំពោះមូលហេតុនេះ គឺមានលក្ខណៈដូចខាងក្រោម ៖

នៅក្នុងបទឃាតកម្ម ជនល្មើសប្រព្រឹត្តនូវអំពើសម្លាប់នេះ ដោយសារខឹងមួយពេល ឬមួយឆាវក៏ជ្រុលខ្លួនប្រព្រឹត្តបទល្មើសទៅ ។ យោងតាមទ្រឹស្តីឧក្រិដ្ឋវិទ្យាបានលើកឡើងថា អ្នកខ្លះធ្លាក់ខ្លួនប្រព្រឹត្តបទល្មើស គឺដោយសារកំហុសនៃជនរងគ្រោះបានន័យថា ជនរងគ្រោះ គឺជាដើមចមនៃបទល្មើសដូចជាការប្រើអំណាចគាបសង្កត់ទៅលើគេខ្លាំងពេកទើបគេទ្រាំលែងបានក៏ប្រព្រឹត្តបទល្មើសមកលើខ្លួនទៅ ឬជនរងគ្រោះជាអ្នកបង្កហេតុមុនគេក៏ថាបានឬមួយអាចស្រដៀងនឹងការការពារស្របច្បាប់តែជាការការពារហួសព្រំដែន ។

ឧទាហរណ៍១ ៖ អ្នកមានអំណាចខ្លះ បានបំពានរំលោភយកដីស្រែរបស់ប្រជាពលរដ្ឋ ហើយដោយសារតែពួកគាត់អត់ដីធ្វើស្រែប្រៀបដូចជាគ្មានអ្វីចិញ្ចឹមជីវិតនោះ ខុសខ្លួនមួយពេលក៏សម្លាប់អ្នកនោះចោលទៅដើម្បីយកដីនោះមកចញ្ចឹមជីវិតខ្លួនឯងវិញ។

ឧទាហរណ៍២ ៖ **ក** ពេលឃើញគេវាយធ្វើបាបឪពុកម្តាយខ្លួនយ៉ាងឃោរឃៅ លុះទ្រាំលែងបានហើយ ដោយសារតែគាត់ខឹងខ្លាំងណាស់ ដូច្នេះដើម្បីការពារអ្នកមានគុណខ្លួនក៏សម្លាប់អ្នកនោះចោលបាត់ទៅ។

ចំណែកឯបទឃាតកម្មគិតទុកជាមុន អំពើនេះអាចកើតដោយសារមានការគុំគួនយូរមកហើយ តែនៅបន្តសងសឹកទៀត។

ឧទាហរណ៍ ៖ **ក** បន្ទាប់ពីឃើញគេសម្លាប់ឪពុកម្តាយខ្លួន ហើយដោយសារតែគ្មានភស្តុតាង និងសាក្សីគ្រប់គ្រាន់តុលាការអាចដោះលែង។ លុះខឹងសម្បារសម្បើមពេកនឹងជនល្មើស គាត់ក៏ទិញដាវស៊ាំម៉ារៃយកមកសំលៀងយ៉ាងមុត ដើម្បីទុកសងសឹកដោយសារតែមានគំនុំជាយូរមកហើយជាមួយជននោះ ។ ម្យ៉ាងគាត់ដឹងថាជននោះច្រើនតែដើរតាមផ្លូវទៅផឹកស្រានៅពេលយប់ លុះដល់យប់ឡើងគាត់ក៏អង្គុយ ចាំជនដែលសម្លាប់ម៉ែឪគាត់អស់មួយរយៈស្រាប់តែពេលឃើញជនហ្នឹងមកដល់ គាត់បានទាញដាវសាំម៉ារៃកាប់ហើយកាប់ទៀតរហូតដាច់ក្បាល ដាច់ដៃ ដាច់ជើង ដាច់អស់រលីង ។

### ខ.លទ្ធភាពក្នុងការកែខ្លួនរបស់ជនល្មើស

នៅក្នុងការបកស្រាយអំពីលទ្ធភាពក្នុងការកែខ្លួនរបស់ជនល្មើសនេះ គឺមានគោលបំណងដើម្បីធ្វើការបប្រៀបធៀបនូវចំណុចខុសគ្នារវាងបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ដោយពាក់ព័ន្ធទៅនឹងកម្រិតនៃការកែខ្លួនរបស់ជនល្មើសដែលមានកម្រិតខុសគ្នាដូចខាងក្រោម៖

នៅក្នុងបទឃាតកម្ម ជនល្មើស គឺជាបុគ្គលដែលអាចនៅកែខ្លួនបាន គឺសំដៅដល់ជនដែលគាត់ខុសខ្លួនតែមួយភ្លែតទេ ក៏បានប្រព្រឹត្តបទល្មើសផ្ទុយទៅវិញ ប្រសិនបើជាទុកឱ្យគាត់បានពិចារណាក្នុងរយៈពេលយូរបន្តិចនោះគាត់នឹងមិនអាចទៅសម្លាប់គេឡើយ ហើយនៅពេលដែលគាត់សម្លាប់គេរួចក៏ភ័យខ្លួនឯងញ័រដៃញ័រជើង និងទើបតែដឹងថាស្តាយក្រោយខ្លាំងណាស់ ដូច្នេះជនប្រភេទនេះ គឺគាត់អាចនៅកែខ្លួនបាន បើសិនជាយើងផ្តល់ឱកាសដល់គាត់នោះ ។

ផ្ទុយទៅនឹងបទឃាតកម្មខាងលើ បទឃាតកម្មគិតទុកជាមុន ជនល្មើសដែលបានប្រព្រឹត្តនូវអំពើនេះហើយ កម្រិតក្នុងការកែខ្លួនរបស់ជនល្មើសមានកម្រិតទាបជាង យើងអាចនិយាយបានថាជាបុគ្គលដែលអស់កែខ្លួនកើតហើយ ។ អ្នកប្រព្រឹត្តអំពើបែបៗនេះ គឺជាប្រភេទមនុស្សដែលមានចរិកលក្ខណៈឃោរឃៅ យង់ឃ្នង ព្រៃផ្សៃ និង អមនុស្សធម៌ខ្លាំងណាស់នៅក្នុងចិត្តរបស់គេ ហើយអាចជាមនុស្សដែលមិនអាចកែខ្លួនកើតនោះឡើយ។

ឧទាហរណ៍១ ៖ បុរសម្នាក់គាត់បានស្រឡាញ់គ្នាជាមួយនារីម្នាក់ និងទំមុនស្រគៀលថែមទៀតហើយ ថែមទាំងបានរស់នៅជាមួយគ្នាដូចប្តីប្រពន្ធអញ្ចឹង ។ ដោយសារនារីស្រឡាញ់បុរសនោះពេក

ក៏យកប្លង់ដី និងផ្ទះទៅបញ្ចាំយកលុយមកទិញម៉ូតូឱ្យបុរសនោះរត់ឌុប។ ស្រាប់តែចាប់ផ្ដើមឡើងទ្រើង បុរសនោះក៏ទៅស្រឡាញ់នារីផ្សេងទៅវិញ ហើយដោយសារតែខ្លាចនារីមុនខឹងក៏រៀបចំគម្រោងឱ្យមិត្តភក្តិទៅចាំនៅក្នុងព្រៃជ្រៅមុន ។ លុះក្រោយពេលពីបាននាំនារីល្អនោះទៅញ៉ាំអីរួចហើយ បុរសថោកទាបនេះក៏បានដឹកនាងនារីដ៏គួរឱ្យអាណិតហ្នឹងចូលក្នុងព្រៃជ្រៅនោះ រួចក៏រួមគ្នាពីរនាក់ពួកម៉ាក់សម្លាប់នាងចោលទៅ។

<u>ឧទាហរណ៍២</u> ៖ ក្រោយពីរាំជាន់ជើងគេ គេក៏ទះខ្លួនមួយកំផ្លៀងតែ **គ** អត់មាត់ទេគឺនៅស្ងៀមឈឹង រួចក៏ត្រឡប់ទៅផ្ទះវិញ។ ក្រោយពេលកន្លងបានមួយសប្តាហ៍ទៅហើយ នៅតែមិនទាន់បាត់ខឹងទៀត ដូច្នេះ **គ** ក៏យកកាំភ្លើងទៅរង់ចាំស្ងាត់ៗ នៅពេលឃើញអ្នកវ៉ៃខ្លួនចេញពីធ្វើការក៏ជិះម៉ូតូតាមគេពីក្រោយរួចបានបាញ់ទម្លុះក្បាលគេពីក្រោយស្លាប់បាត់ទៅ ។ ហេតុនេះ រយៈពេលប៉ុណ្ណឹងទៅហើយនៅតែមិនគិតអ្វីផ្សេងក្រៅតែពីសម្លាប់គេទៀតនេះ គឺបានន័យថាជនល្មើសមួយនេះអស់កែខ្លួនលែងកើតហើយ ។

### ច.គោលដៅរបស់ជនល្មើសចំពោះជនរងគ្រោះ

គោលដៅរបស់ជនល្មើសចំពោះជនរងគ្រោះ ក៏ជាចំណុចមួយដែលបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនមានលក្ខណៈខុសគ្នាដែរ ។ នៅក្នុងផ្នែកនេះ យើងចង់បកស្រាយអំពីភាពខុសគ្នារវាងបទល្មើសទាំងពីរទៅលើកម្រិតនៃការយល់ដឹងដែលជនល្មើសមានចំពោះជនរងគ្រោះ ហើយមានលក្ខណៈខុសគ្នាដូចខាងក្រោម៖

នៅក្នុងបទឃាតកម្ម ជនល្មើសអាចស្គាល់ ឬ មិនស្គាល់ជនរងគ្រោះ ពីព្រោះតែបទល្មើសនេះកើតឡើងនៅក្នុងរយៈពេលមួយខ្លី ហេតុនេះហើយចំពោះបុគ្គលដែលខ្លួនមិនស្គាល់ពីមុនមកនៅក្នុងពេលប្រព្រឹត្តបទល្មើសក៏នៅតែមិនស្គាល់ដែរ ។ ជួនកាលជនល្មើសអាចសម្លាប់មិត្តភក្តិដែលស្គាល់គ្នាដោយសារតែទាស់ទែងគ្នាមួយភ្លែត ឬ ជនល្មើសអាចសម្លាប់អ្នកមិនស្គាល់គ្នាក៏ថាបានដូចជាខឹងអ្នកគប់ទឹកដែលបានធ្វើឱ្យប្រពន្ធខ្លួនដួលម៉ូតូបាក់ជើង ក៏ទាញកាំភ្លើងបាញ់គេស្លាប់ភ្លាមៗទាន់ហ៊ាន់តែម្តង។

ចំណែកឯនៅក្នុងបទឃាតកម្មគិតទុកជាមុនវិញនោះ ជនល្មើសបានស្គាល់ជនរងគ្រោះច្បាស់លាស់បានន័យថា មុននឹងគាត់ដាក់ចិត្តតាមសម្លាប់អ្នកណាមួយ គឺគាត់ស្គាល់អ្នកនោះច្បាស់ណាស់ហើយ ឬ ជនល្មើសបានតាមដាន ស៊ើបសួរ ឬបានស្គាល់ពីអត្តសញ្ញាណជននោះរួចរាល់អស់ហើយមុនសម្លាប់ ។ មូលហេតុដែលជនល្មើសបានស្គាល់ជនរងគ្រោះច្បាស់ ដោយសារតែបទល្មើសនេះកើតឡើងក្នុងរយៈពេលមួយដែលជនល្មើស អាចគិតពិចារណាច្រើននៅក្នុងការសម្រេចចិត្តថាប្រព្រឹត្តនូវអំពើនេះ ហើយទើបឈានទៅដល់ការរៀបចំនូវគម្រោងរបស់ខ្លួន ។

**៣.២.២.៣.ធាតុផ្សំអត្តនោម័ត**

នៅក្នុងធាតុផ្សំអត្តនោម័ត ក៏មានចំណុចខុសគ្នារវាងបទឃាតកម្ម និងឃាតកម្មគិតទុកជាមុនផងដែរ មិនមែនមានតែធាតុផ្សំនីត្យានុកូល និងធាតុផ្សំសត្យានុម័តតែប៉ុណ្ណោះនោះទេ ។ ចំណុចខុសគ្នានៅក្នុងធាតុផ្សំអត្តនោម័តរវាងបទល្មើសទាំងពីរនេះ គឺសំដៅទៅលើចេតនាទុច្ចរិតរបស់ជនល្មើសនៅក្នុងការប្រព្រឹត្តនូវបទល្មើស ហើយដែលចេតនានេះវាពាក់ព័ន្ធទៅនឹងពេលវេលាសម្រាប់ការពិចារណារបស់ជនល្មើស ហើយចំណុចខុសគ្នានេះមានលក្ខណៈដូចខាងក្រោម៖

ចំពោះបទឃាតកម្ម ជនល្មើសមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសដើម្បីដកហូតយកជីវិតជនរងគ្រោះដោយផ្ទុយច្បាប់ ប៉ុន្តែចេតនាទុច្ចរិតមិនបានឆ្លងកាត់ការគិតទុកជាមុនដែលអាចធ្វើឱ្យជនល្មើសរៀបចំគម្រោងច្បាស់លាស់នោះទេ។

ផ្ទុយទៅនឹងបទឃាតកម្មខាងលើនេះ បទឃាតកម្មគិតទុកជាមុន ជនល្មើសមានចេតនាទុច្ចរិត ដោយបានគិតទុកជាមុន ឬដោយបានពួនស្ទាក់តាមរយៈពេលវេលាក្នុងការរៀបចំគម្រោងក្នុងគោលបំណងប្រព្រឹត្តអំពើដែលផ្ទុកលទ្ធភាពពិសេស ដើម្បីប្រល័យជីវិតជនរងគ្រោះ ។

**៣.២.៣.ទោសដែលត្រូវអនុវត្ត**

បើយើងធ្វើការពិនិត្យទៅលើការបកស្រាយចំពោះទោសដែលត្រូវអនុវត្តនេះ យើងសង្កេតឃើញថា បទល្មើសឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន មានចំណុចខុសគ្នាដោយពាក់ព័ន្ធនឹងទោសនេះចំនួនពីរចំណុច។

**៣.២.៣.១.មូលទោស**

មូលទោស ដោយយើងស្គាល់ថាជាទោសដែលដាក់ទណ្ឌកម្មទៅលើជនល្មើស ដោយមានការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់នោះ ក៏ជាចំណុចខុសគ្នាមួយដែររវាងបទល្មើសទាំងពីរ ។ ប៉ុន្តែចំណុចខុសគ្នានេះមានលក្ខណៈងាយស្រួលនៅក្នុងការពិនិត្យមើល ដោយមានចែងនៅក្នុងក្រមព្រហ្មទណ្ឌយ៉ាងច្បាស់លាស់តែម្តងដោយមានការកំណត់នៅក្នុងមាត្រាជាក់ស្តែង។ មូលទោសនៃបទឃាតកម្ម គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ១៩៩។

ចំណែកឯមូលទោសនៃបទឃាតកម្មគិតទុកជាមុនវិញ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ២០០ ។

**៣.២.៣.២.ស្ថានទម្ងន់ទោស**

ស្ថានទម្ងន់ទោស គឺសំដៅទៅលើការបន្ថែមនូវកម្រិតនៃទោសឱ្យកាន់តែធ្ងន់ធ្ងរជាងមុនទៅទៀត ហើយចំណុចនេះក៏មានលក្ខណៈខុសគ្នាមួយចំនួនរវាងបទល្មើសឃាតកម្ម និងឃាតកម្មគិតទុកជាមុន ។

នៅក្នុងបទឃាតកម្មទោស ដែលត្រូវដាក់ទៅលើជនល្មើស អាចដាក់ស្ថានទម្ងន់ទោសបាន ប្រសិនបើប្រព្រឹត្តចូលក្នុងករណីនៃស្ថានទម្ងន់ទោសជាក់លាក់ដូចមានចែងពីមាត្រា ២០០ ដល់ មាត្រា ២០៥ ។ ប៉ុន្តែបទល្មើសនេះគ្មានស្ថានទម្ងន់ទោសទេ ប្រសិនបើជនល្មើសមិនបានប្រព្រឹត្តនូវ អំពើសម្លាប់ចូលទៅក្នុងមាត្រា ២០០ ដល់ មាត្រា ២០៥ បានន័យថា គាត់ប្រព្រឹត្តបទឃាតកម្មដោយ គ្មានការគិតទុកជាមុន, គ្មានការប្រើថ្នាំពុល, គ្មានទាក់ទងទៅនឹងជនរងគ្រោះ, គ្មានដោយសារ គោលដៅ, មិនមែនប្រព្រឹត្តដោយអ្នករាជការសាធារណៈ និងមិនមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈនោះទេ ។ សរុបមក គឺជនល្មើសប្រព្រឹត្តតែអំពើដែលចូលត្រឹមមាត្រា ១៩៩ "បទឃាតកម្ម" តែប៉ុណ្ណោះ ។

បើយើងធ្វើការពិនិត្យទៅលើបទឃាតកម្មគិតទុកជាមុនវិញ មូលទោសដែលដាក់ទៅលើជន ល្មើសមិនអាចដាក់ស្ថានទម្ងន់ទោសថែមទៀតបានទេ ពីព្រោះបទឃាតកម្មគិតទុកជាមុន គឺជាបទ ល្មើសដែលមានស្ថានទម្ងន់ទោសខ្ពស់ជាងគេណាស់ទៅហើយ ព្រោះទោសដាក់ពន្ធនាគារ គឺអស់ មួយជីវិត។ ម្យ៉ាងវិញទៀត បទឃាតកម្មគិតទុកជាមុន ជាប្រភេទមួយនៃស្ថានទម្ងន់ទោសរបស់ មាត្រា ១៩៩ គឺដោយសារតែនៅក្នុងមាត្រា ១៩៩ មានស្ថានទម្ងន់ទោសទាំងអស់ ៦ ប្រភេទ គិត ចាប់ពីមាត្រា ២០០ ដល់មាត្រា ២០៥។ ដូច្នេះឃាតកម្មគិតទុកជាមុន គឺជាប្រភេទទីមួយនៃបទ ឃាតកម្មនេះឯង។

ខ្ញុំបានបញ្ចប់នូវការបកស្រាយទាំងបី ជំពូករួចហើយ។ ប៉ុន្តែមុននឹងបញ្ចប់សៀវភៅមួយនេះ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានវាយតម្លៃចំណុចខ្លាំង និងខ្សោយ រួចនឹងផ្ដល់អនុសាសន៍បញ្ចប់តែម្ដង។ សូមអរគុណ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីរបានធ្វើការសិក្សាទៅលើបទឃាតកម្ម និងបទឃាតកម្មទុកជាមុន យើងសង្កេតឃើញថាវាមានចំណុចដូចគ្នាជាច្រើន ចំណែកឯចំណុចខុសគ្នាក៏មានច្រើនផងដែរ ។ ចំណុចដូច និងខុសគ្នាត្រូវបានបង្ហាញនៅក្នុងការប្រៀបធៀបរវាងបទល្មើសទាំងពីរ ហេតុនេះមុននឹងឈានទៅដល់ការប្រៀបធៀប យើងត្រូវធ្វើការសិក្សាទៅលើបទល្មើសនីមួយៗជាមុនសិន ។

បទឃាតកម្មសំដៅទៅលើអំពើសម្លាប់មនុស្ស ដែលកើតឡើងដោយចេតនារបស់ជនល្មើស ហើយអាចប្រើអាវុធ ឬមិនប្រើអាវុធក្តី ។ បទល្មើសនេះត្រូវបានចែងនៅក្នុងមាត្រា ១៩៩នៃក្រមព្រហ្មទណ្ឌ ហើយនៅក្នុងធាតុជាសម្ភារៈនៃបទល្មើសនេះ គឺទាមទារឱ្យមានត្រឹមតែអំពើដែលផ្ទុកនូវលទ្ធភាពក្នុងការដកហូតជីវិតមនុស្សតែប៉ុណ្ណោះ មិនទាមទារឱ្យមានព្យសនកម្មកើតឡើងនោះទេ ។ ចំណែកឯធាតុអត្តនោម័តវិញ គឺសំដៅទៅលើចេតនារបស់ជនល្មើសនៅក្នុងពេលប្រព្រឹត្តអំពើសម្លាប់ ហើយចេតនានេះអាចកើតចេញពីបុគ្គលផ្ទាល់ ករណីមានការយល់ព្រមពីជនរងគ្រោះ ការការពារខ្លួនស្របច្បាប់ និងការភ័ន្តច្រឡំ ។ លើសពីនេះទៅទៀត បទឃាតកម្មក៏មាននូវស្ថានទម្ងន់ទោសផងដែរ ប្រសិនបើអំពើសម្លាប់កើតឡើងនៅក្នុងករណីមួយដូចជា ការគិតទុកជាមុន ឬការពួនស្ទាក់ ការប្រើប្រាស់ថ្នាំពុល ស្ថានភាពជនរងគ្រោះទន់ខ្សោយ ឬជាអ្នករាជការសាធារណៈ ស្ថានទម្ងន់ទោសមានគោលដៅ ជនល្មើសជាអ្នករាជការសាធារណៈ និងមានអំពើឃោឃៅ ឬរំលោភសេពសន្ថវៈ គឺ ស្ថានទម្ងន់ទោស ។ ចំពោះទោសបន្ថែមវិញ មានចែងនៅក្នុងមាត្រា២០៦ នៃក្រមព្រហ្មទណ្ឌ ដែលមានប្រាំបួនចំណុច ។

បើយើងធ្វើការពិនិត្យទៅលើបទល្មើសឃាតកម្មគិតទុកជាមុន គឺសំដៅទៅលើអំពើសម្លាប់ដោយឆ្លងកាត់ ការគិតទុកជាមុន ឬការពួនស្ទាក់។ បទល្មើសនេះត្រូវបានចែងនៅក្នុងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ហើយធាតុសម្ភារៈនៃបទល្មើសនេះ គឺទាមទារនូវអំពើដកហូតជីវិតមនុស្ស ដោយមិនទាមទារឱ្យមានព្យសនកម្មកើតឡើងដូចបទឃាតកម្មដែរ ប៉ុន្តែមានថែមនូវស្ថានភាពពីរទៀត គឺការគិតទុកជាមុន និងការពួនស្ទាក់ ។ ចំណែកឯធាតុអត្តនោម័តនៃបទល្មើសនេះ ក៏ដូចគ្នាទៅនឹងបទឃាតកម្មដែរ ប៉ុន្តែខុសគ្នាត្រង់ថា ធាតុចេតនានៃបទឃាតកម្មគិតទុកជាមុន កើតឡើងដោយមានការគិតទុកជាមុន ឬរៀបចំគម្រោង មធ្យោបាយ ឬឧបករណ៍ និងមានការពួនស្ទាក់មុនពេលប្រព្រឹត្តនូវអំពើសម្លាប់។ លើសពីនេះទៅទៀតបទល្មើសនេះត្រូវបានផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ហើយទោសបន្ថែមដូចគ្នាទៅនឹងបទឃាតកម្មផងដែរ គឺនៅក្នុងមាត្រា២០៦ នៃក្រមព្រហ្មទណ្ឌ។

បន្ទាប់ពីបានធ្វើការសិក្សាទៅលើបទទាំងពីរខាងលើរួចមក យើងអាចទាញនូវចំណុចមួយចំនួនយកមកធ្វើការប្រៀបធៀប ដោយលើឡើងជាចំណុចដូចគ្នា និងចំណុចខុសគ្នា។

បទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនមានចំណុចដូចគ្នាមួយចំនួន ។ បទល្មើសទាំងពីរត្រូវបានចែងនៅក្នុងរចនាសម្ព័ន្ធនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដូចគ្នា ហើយប្រភេទនៃបទល្មើសទាំងពីរ គឺបទឧក្រិដ្ឋ ។ ចំណែកឯបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើស ដូចជា ចារី ឬសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត និងជនរងគ្រោះមានដូចគ្នា ហើយអំពើ និងបច្ច័យក៏មិនខុសគ្នាដែរ គឺទាមទារឱ្យមាននូវអំពើ មិនទាមទារឱ្យមាននូវព្យសនកម្មឡើយ ។ ចំពោះអាជ្ញាយុកាល បទល្មើសទាំងពីរ គឺ១៥ ឆ្នាំ ចំពោះបទល្មើស និង ២០ឆ្នាំ ចំពោះទោស ហើយបើលើកឡើងពីរទោសបន្ថែម និងការប៉ុនប៉ង ក៏មានលក្ខណៈដូចគ្នាផងដែរ គឺទោសបន្ថែមមានចែងនៅក្នុងមាត្រា ២០៦ និងការប៉ុនប៉ងនៅក្នុងមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ។

ផ្ទុយទៅវិញបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន ក៏មានចំណុចមួយចំនួនដែលខុសគ្នាផងដែរ ។ និយមន័យនៃបទល្មើសទាំងពីរខុសគ្នាត្រង់ថា បទឃាតកម្មគិតទុកជាមុនមានបន្ថែមនូវការគិតទុកជាមុន ឬការពួនស្ទាក់ ហើយធាតុផ្សំនៃបទល្មើសក៏មិនដូចគ្នាដែរ គឺធាតុនីត្យានុកូលមានចែងនៅក្នុងមាត្រា ១៩៩ ចំពោះបទឃាតកម្ម និង មាត្រា ២០០ ចំពោះបទឃាតកម្មគិតទុកជាមុន ។ ចំណែកឯធាតុសត្យានុម័តខុសគ្នានៅត្រង់ថា បទឃាតកម្មគិតទុកជាមុន បន្ថែមសញ្ញាណពីរគឺការគិតទុកជាមុន និងការពួនស្ទាក់ នៅក្នុងអំពើសត្យានុម័ត ហើយធាតុអត្តនោម័តខុសត្រង់ថាចេតនាប្រព្រឹត្តអំពើសម្លាប់ត្រូវឆ្លងកាត់ការពួនស្ទាក់ ឬ ការគិតទុកជាមុន ចំពោះបទឃាតកម្មគិតទុកជាមុន។ ចំពោះទោសដែលត្រូវអនុវត្តក៏មានលក្ខណៈដូចគ្នាផងដែរ គឺចំពោះមូលទោស បទឃាតកម្ម មានចែងនៅក្នុងមាត្រា ១៩៩ និង មាត្រា២០០ ចំពោះបទឃាតកម្មគិតទុកជាមុន ។

សរុបជារួមមកបទល្មើសទាំងពីរនេះ ទោះជាបទល្មើសទាំងពីរនេះត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះក៏ដោយ ក៏មិនត្រឹមតែមានគុណសម្បត្តិទេ គឺមាននូវគុណវិបត្តិផងដែរ ។

បទល្មើសទាំងពីរនេះ មាននូវអត្ថប្រយោជន៍មួយចំនួនដែលជាគោលបំណងនៃការចែងនូវបទល្មើសទាំងពីរនេះឡើង ។ បទល្មើសទាំងពីរនេះ ត្រូវបានចែងឡើងដោយគោរពទៅតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ ដែលមាត្រានេះបានធានានូវសិទ្ធិរស់រានមានជីវិត និងហាមឃាត់មិនឱ្យមាននូវទោសប្រហារជីវិត ពីព្រោះបទល្មើសទាំងពីរនេះចែងនៅក្នុងគោលបំណងហាមឃាត់ ទប់ស្កាត់បង្ការកុំឱ្យមាននូវអំពើសម្លាប់មនុស្ស និងដាក់ទោសទៅលើបុគ្គលដែលបានប្រព្រឹត្តនូវអំពើសម្លាប់នោះ។ លើសពីនេះបទល្មើសទាំងពីរនេះ ត្រូវបានចែងដោយកំណត់នូវទោសដាក់ពន្ធនាគារ តែ

ប៉ុណ្ណោះ មិនមាននូវទោសប្រហារជីវិតនោះទេ ទោះបីជាវាប៉ះពាល់ដល់អាយុជីវិតមនុស្សក៏ដោយ ប៉ុន្តែបើនៅក្នុងច្បាប់ចាស់សម័យពីមុនវិញ គឺដាក់ទោសប្រហារជីវិតតែម្តង ។ បទល្មើសទាំងពីរនេះត្រូវបានចែងដោយដាក់នូវទោសដាក់ពន្ធនាគារ គឺសមល្មមនឹងកម្រិតផលប៉ះពាល់នៃបទល្មើសដែលធ្វើឱ្យប្រធាននៃបទល្មើសមានការខ្លាចរអារ និងរៀងចាលមិនហ៊ានប្រព្រឹត្តបទល្មើសទាំងពីរនេះឡើយ ។ បើពិនិត្យមើលទៅបទឃាតកម្ម មិនត្រឹមតែដាក់ទោសទៅលើអំពើសម្លាប់ធម្មតានោះទេ ថែមទាំងបានពង្រីកវិសាលភាពដល់អំពើសម្លាប់ដែលកើតឡើងនៅក្នុងស្ថានភាពពិសេសៗ មួយចំនួនទៀតដូចបានរៀបរាប់ខាងលើ ហើយចាត់ទុកអំពើសម្លាប់នេះជាស្ថានទម្ងន់ទោស ។

បទល្មើសទាំងពីរត្រូវបានចែងឡើងដោយផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែនៅក្នុងនោះក៏មាននូវចំណុចអវិជ្ជមានមួយចំនួនផងដែរ ។ បទល្មើសទាំងពីរនេះមានលក្ខណៈស្រដៀងគ្នា ខុសគ្នាត្រង់បទឃាតកម្មគិតទុកជាមុនមាន ការគិតទុកជាមុន ឬការពួនស្ទាក់តែប៉ុណ្ណោះ ហើយចំណុចដែលធ្វើឱ្យយើងមានការពិបាកក្នុងការបែងចែកបទល្មើសទាំងពីរឱ្យដាច់ពីគ្នា គឺនៅត្រង់ចំណុច **ការគិតទុកជាមុន**នេះតែម្តង ។ យើងមានការលំបាក់នៅក្នុងការកំណត់នូវអំពើសម្លាប់ណាមួយដែលបង្កប់នូវចេតនារបស់ជនល្មើសដែលកើតឡើងតាមរយៈការគិតទុកជាមុន ហេតុនេះហើយក៏អាចមានការបកស្រាយ និងការសម្រេចសេចក្តីរបស់តុលាការមានការខុសឆ្គងដោយច្រឡំទៅលើបទល្មើសទាំងពីរនេះ ។ ចំពោះបទល្មើសដែលជាស្ថានទម្ងន់ទោសនៃបទឃាតកម្ម គឺបទឃាតកម្មដោយមានអំពើទារុណកម្ម អំពើឃោឃៅ និងអំពើរំលោភសេពសន្ថវៈ ។ បទល្មើសនេះវាមានការលំបាកនៅក្នុងការកំណត់ទៅលើស្ថានភាពនៃការប្រព្រឹត្តនូវអំពើសម្លាប់នៅក្នុង និងក្រោយពេលមានអំពើទាំងនេះ ដូចជាករណីមានការសម្លាប់ក្រោយពេលរលោភសេពសន្ថវៈ ករណីនេះអាចមានការកំណត់នូវបទល្មើសខុស គឺអាចកំណត់ថាមានបទល្មើសពីរ ទីមួយបទឃាតកម្ម និងទីពីរបទរំលោភសេពសន្ថវៈ ដែលមានការកំណត់ទោសខុសគ្នាទៅនឹងស្ថានទម្ងន់ទោសខាងលើ ។

បន្ទាប់ពីរធ្វើសេចក្តីសន្និដ្ឋានរួចមក នាងខ្ញុំសូមបញ្ចេញនូវមតិយោបលផ្ទាល់ខ្លួនមួយចំនួនដែលពាក់ព័ន្ធទៅនឹងចំណុចខ្វះខាតមួយចំនួននៃបទល្មើសទាំងពីរខាងលើនេះនៅចំណុច ដែលលើកឡើងជាអនុសាសន៍នៅក្នុងចំណុចបន្ទាប់នេះ ។

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាទៅលើបទល្មើសនីមួយៗ និងការប្រៀបធៀបនៃបទល្មើសទាំងពីររួចមក យើងក៏បានសង្កេតឃើញនូវចំណុចដែលជាគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនដូចបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានខាងលើផងដែរ ។

ដោយសង្កេតឃើញនូវចំណុចអវិជ្ជមាននៃបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុនខាងលើនេះ ដើម្បីឱ្យការអនុវត្តន៍នូវបទល្មើសទាំងពីរខាងលើនេះប្រកបដោយភាពរលូន នាងខ្ញុំសូមធ្វើការផ្តល់នូវមតិយោបល់មួយចំនួនដោយបែងចែកជាចំណុចសំខាន់ៗដូចខាងក្រោម៖

**១.គោលនយោបាយអនុវត្ត៖**

សំដៅទៅលើការចែងអំពីបទល្មើសទាំងពីរនៅក្នុងក្រមព្រហ្មទណ្ឌ គឺធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលយល់ដោយធ្វើបែងចែកនូវបទល្មើសទាំងពីរឱ្យបានច្បាស់លាស់ ជាពិសេសធ្វើការកំណត់នូវ សញ្ញាណនៃបទឃាតកម្មគិតទុកជាមុន គឺការគិតទុកជាមុន ដែលពិបាកក្នុងការកំណត់នូវភាពខុសគ្នារវាងបទឃាតកម្ម និងបទឃាតកម្មគិតទុកជាមុន ។

លើសពីនេះទៅទៀត ចំពោះការចែងអំពីស្ថានទម្ងន់ទោសក៏ត្រូវធ្វើឱ្យបានច្បាស់លាស់ផងដែរ ពីព្រោះការដាក់ទោសទៅលើបទល្មើសវាមានទម្ងន់ខុសគ្នា ដូចជាការសម្លាប់ក្រោយពេលរំលោភសេពសន្ថវៈជាដើម ដែលអាចកំណត់ចេញជាបទល្មើសពីរ គឺបទឃាតកម្ម និងបទរំលោភសេពសន្ថវៈ ធ្វើឱ្យការសម្រេចនូវទោសទៅលើជនល្មើសខុសគ្នារវាងស្ថានទម្ងន់ទោសនៃបទឃាត កម្ម និងការកំណត់ចេញជាបទល្មើសពីរនេះ ។

**២.ការបណ្តុះបណ្តាល** គឺជាចំណែកមួយយ៉ាងសំខាន់ដែលចូលរួមនៅក្នុងការផ្តល់នូវចំណេះដឹងអំពីបទល្មើសទាំងពីរនេះ ប្រសិនបើពុំមានការយល់ដឹងអំពីបទល្មើសទាំងពីរនេះឱ្យបានច្បាស់លាស់នោះទេ ការចូលរួមអនុវត្តក៏មិនមានភាពខ្លាំងក្លាដែរ ។ បុគ្គលដែលត្រូវទទួលការបណ្តុះបណ្តាលមានដូចខាងក្រោម៖

- **ចៅក្រម ៖** ចៅក្រមជាអ្នកអនុវត្តច្បាប់ និងជាអ្នកកាត់សេចក្តីដែលធ្វើឡើងទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ហេតុនេះហើយចៅក្រមត្រូវតែយល់ដឹងឱ្យច្បាស់លាស់ទៅលើប្រភេទនៃបទល្មើសទាំងពីរឱ្យបានច្បាស់លាស់ ដើម្បីជៀសវៀងការចោទប្រកាន់ខុសបទល្មើសចំពោះចៅក្រមអយ្យការ និងការសម្រេចសេចក្តីដាក់ទោសទៅលើ

ជនល្មើសខុសបទល្មើស ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនល្មើស និងដំណើរការនៃនីតិវិធីតុលាការចំពោះចៅក្រមជំនុំជម្រះ។

**៣.ការផ្សព្វផ្សាយ** ជាផ្នែកមួយសំខាន់ដើម្បីបង្កើននូវប្រសិទ្ធិភាពដល់ការអប់រំបណ្តុះបណ្តាល។ ការផ្សព្វផ្សាយនូវចំណេះដឹងអំពីបទល្មើសទាំងពីរនេះទៅដល់ប្រជាពលរដ្ឋ ធម្មតាគឺវាមានសារៈសំខាន់ខ្លាំងណាស់ព្រោះយើងមិនអាចធ្វើការបណ្តុះបណ្តាលឱ្យដល់ប្រជាពលរដ្ឋគ្រប់គ្នា ហើយណាមួយពួកគាត់មិនមែនជាអ្នកអនុវត្តច្បាប់ទេ ហេតុនេះហើយមិនទាមទារជាចាំបាច់ឱ្យពួកគាត់យល់ដឹងច្បាស់លាស់ស៊ីជម្រៅនោះទេ ។

# ឯកសារយោង

## ❖ លិខិតបទដ្ឋានជាតិ

– ក្រមព្រហ្មទណ្ឌ (ចុះថ្ងៃទី៣០ ខែ វិច្ឆកា ឆ្នាំ ២០០៩)
– ច្បាប់ព្រហ្មទណ្ឌអន្តរកាល(ចុះថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ១៩៩២)
– ច្បាប់ស្តីពីការគ្រប់គ្រងអាសុីតខ្លាំង (ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១១)

## ❖ លិខិតបទដ្ឋានអន្តរជាតិ

– ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ៖ មគ្គុទេសន៍សំរាប់ធ្វើការពិភាក្សា អំពីអង្គជំនុំជំម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សេចក្តីព្រាង ខែ ឧសភា ឆ្នាំ ២០០៦)
– ធាតុផ្សំបទឧក្រិដ្ឋនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (អនុម័តដោយសន្និបាតនៃរដ្ឋភាគីសម័យប្រជុំលើកទី១ ញូវយ៉ក ថ្ងៃទី ០៣ ដល់ ១០ ខែ តុលា ឆ្នាំ ២០០២)

## ❖ ឯកសារផ្សេងទៀត

– សៀវភៅ នីតិព្រហ្មទណ្ឌ (ឯកឧត្តម ហុី សោភា)
– សៀវភៅ នីតិព្រហ្មទណ្ឌពិសេស (លោកសាស្រ្តាចារ្យ សុខ រឿន)
– សៀវភៅ ព្រហ្មទណ្ឌពិសេស (លោកសាស្រ្តាចារ្យ យឹម សារី)
– សៀវភៅ បទល្មើស និងការផ្តន្ទាទោសក្នុងក្រមព្រហ្មទណ្ឌ (លោកសាស្រ្តាចារ្យ សុខ រឿន)
– សិក្ខាសាលាស្តីពី ផលប៉ះពាល់នៃឥទ្ធិពលគ្រឿងញៀន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ នីតិគ្រួសារ និងដំណោះស្រាយជំលោះអន្តរជាតិ ថ្ងៃទី ១៨-១៩-២០ ខែ តុលា ឆ្នាំ២០១០ នៅបញ្ជាការដ្ឋានកងពលតូចលេខ៧០ (លោកសាស្រ្តាចារ្យ វុណ្ណរិទ្ធ និងលោកស្រីចៅក្រម ចាំង ស៊ីណាត)
– សិក្ខាសិលាបណ្តុះបណ្តាលក្រមព្រហ្មទណ្ឌ
– ឯកសារសិក្សា (ឯកឧត្តម ប៊ុន ហុន)
– សន្ទានុក្រមព្រហ្មទណ្ឌ (ចុះថ្ងៃទី៣១ ខែ មិនា ឆ្នាំ ២០១១)
– វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០៩

## ❖ ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ

– ឯកសារក្នុងអ៊ិនធឺណេត (www.khmer.rfi.com)
– ឯកសារក្នុងអ៊ិនធឺណេត (www.kohsontepheap.com)
– ឯកសារក្នុងអ៊ិនធឺណេត (www.reksmeykompuchea.com)
– The Bar Association of the Kingdom of Cambodia :
*(http://www.bakc.org.kh/lawdocument.php)*
– The Research and Promotion Khmer Laws Association :
*(http://www.khmerlaws.com, http://www.khmerlaws.org, http://www.khmerlaws.info)*
– សារព័ត៌មាន កោះសន្តិភាព
– សារព័ត៌មាន រស្មីកម្ពុជា

# សេចក្ដីផ្ដើម

# ជំពូកទី១

# បនយាតកម្ម

# ជំពូកទី២

# បទឃាតកម្មគិតទុកជាមុន

# ជំពូកទី៣
# ការប្រៀបធៀបបទ
# ល្មើសទាំងពីរ

# សេចក្តីសន្និដ្ឋាន

# អនុសាសន៍

# ឯកសារយោង

# ឧបសម្ព័ន្ធ